# ដឹងអំពី សិទ្ធិរបស់អ្នក

## ការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺរបេង


ដោយ **GISA DANG**

កែសំរួលដោយ Tsira Chakhaia, Brian Citro, Vivian Cox, Mike Frick, Jennifer Furin, Erica Lessem, Alexander William Mbuya, Lindsay McKenna, John Mdluli, Jane Rahedi Ong’ang’o, Hadija H. Semvua, and Zani de Wit






# ដឹងអំពីសិទ្ធិរបស់អ្នក

## ការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺរបេង

## សិទ្ធិមនុស្ស និងជំងឺរបេង

ដោយ **GISA DANG**

កែសំរួលដោយ Tsira Chakhaia, Brian Citro, Vivian Cox, Mike Frick, Jennifer Furin, Erica Lessem, Alexander William Mbuya, Lindsay McKenna, John Mdluli, Jane Rahedi Ong'ang'o, Hadija H. Semvua, and Zani de Wit



### ហេតុអ្វីត្រូវមានសេចក្តីណែនាំនេះ ?

សេចក្តីណែនាំនេះ គឺសម្រាប់អ្នកដែលមានជំងឺរបេង មនុស្សដែលងាយរងគ្រោះពីជំងឺរបេង និងអ្នកដែលផ្តល់ការថែទាំអ្នកជំងឺរបេង។ សេចក្តីណែនាំនេះមានគោលបំណងពន្យល់ពីស្តង់ដារសាកល សម្រាប់ការថែទាំជំងឺរបេង ដែលរួមមានទាំងសេវាផ្សេងៗ ដែលអ្នកមានសិទ្ធិត្រូវទទួលបាន។ សេចក្តីណែនាំនេះ មានគោលបំណងបញ្ជាក់ពីសិទ្ធិរបស់អ្នក ទាក់ទងទៅនឹងការការពារជំងឺរបេង ការធ្វើតេស្ត ការព្យាបាល និងការថែទាំ។ គោលដៅរបស់យើង គឺសម្រាប់មនុស្សដែលទទួលរងផលប៉ះពាល់ដោយជំងឺរបេង មានការយល់ដឹងថា តើនៅពេលណា ដែលពួកគេ នឹងទទួលបានការថែទាំដែលមានកម្រិតខ្ពស់បំផុត ដែលអាចជួយអោយពួកគេអោយស្នើសុំនូវស្តង់ដារដែលមានការទទួលស្គាល់ជាសាកល។

### តើអ្វីទៅជាបទដ្ឋានស្តង់ដារដែលមានការទទួលស្គាល់ជាសាកល ?

អង្គការសុខភាពពិភពលោក (WHO) គឺជាអង្គការរបស់សហប្រជាជាតិ (UN) ដែលមានជំនាញខាងផ្នែកសុខភាព។ ផ្នែកមួយនៃការងាររបស់អង្គការសុខភាពពិភពលោកគឺផ្តល់ការណែនាំ ក្នុងដំណើរការនៃការកំណត់ស្តង់ដារ និងគោលការណ៍ណែនាំនានា សម្រាប់ការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺរបេង។ បទដ្ឋានស្តង់ដារទាំងនេះជួយដល់អ្នកធ្វើគោលនយោបាយ និងអាជ្ញាធរសុខាភិបាល ដើម្បីរៀបចំផែនការ និងផ្តល់ជូននូវកម្មវិធីសុខាភិបាលរបស់ប្រទេសពួកគេ ដែលគោរពការពារ និងបំពេញនូវសិទ្ធិរបស់មនុស្សគ្រប់រូប ក្នុងការទទួលបានសេវាសុខភាព និងសិទ្ធិមនុស្សដែលពាក់ព័ន្ធដទៃផ្សេងទៀត។

DR-TB STAT

TAG Treatment Action Group

www.treatmentactiongroup.org

មករា 2018

## តើអ្វីជាសិទ្ធិមនុស្ស និងហេតុអ្វីបានជាវាមានសារៈសំខាន់ចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

អ្នកដែលមានជំងឺរបេង និងអ្នកដែលប្រឈមជាមួយនឹងជំងឺរបេង មានមូលដ្ឋានសិទ្ធិមនុស្សរបស់ពួលគេ។ រដ្ឋាភិបាលមានកាតព្វកិច្ចផ្លូវច្បាប់ក្រោមច្បាប់អន្តរជាតិ ច្បាប់តំបន់ និងច្បាប់ក្នុងស្រុកក្នុងការផ្តល់ការគោរព ការការពារ និងធ្វើឲ្យពួកគេយល់ពីសិទ្ធិមនុស្សទាំងនេះ។ សិទ្ធិមនុស្សគឺមានលក្ខណៈសកល ដែលពួកគេម្នាក់ៗមាន។ សិទ្ធិមនុស្សគឺមិនអាចខណ្ឌផ្តាច់ មានលក្ខណៈអធ្យាស្រ័យគ្នា និងមានទំនាក់ទំនងជាមួយគ្នាផងដែរ។ នោះមានន័យថា សិទ្ធិមនុស្សមានសារៈសំខាន់ស្មើគ្នា ពឹងពាក់គ្នាទៅវិញទៅមក ហើយមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយគ្នា។ បើយកចេញសិទ្ធិណាមួយផ្តល់ផលប៉ះពាល់ដល់សិទ្ធិមួយទៀត។

សិទ្ធិមនុស្សជាច្រើន មានសារៈសំខាន់ចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង។ សិទ្ធិទាំងនេះ មាននៅក្នុងសន្ធិសញ្ញាអន្តរជាតិ និងក្នុងថ្នាក់តំបន់ និងក៏មានចែងក្នុងរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសនីមួយៗក្នុងពិភពលោក។ សិទ្ធិទាំងនោះរួមបញ្ចូល សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសេវាសុខភាព សិទ្ធិមិនត្រូវបានគេរើសអើង សិទ្ធិទទួលបានសេរីភាពពេញលេញ សិទ្ធិទទួលបានផ្នែកវិទ្យាសាស្ត្រ សិទ្ធិទទួលការពិគ្រោះយោបល់ សិទ្ធិទទួលព័ត៌មាន សិទ្ធិឯកជនភាព សិទ្ធិក្នុងការចូលរួម សេរីភាពពីការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក សេរីភាពក្នុងការធ្វើដំណើរសេរីភាពពីការឃុំខ្លួនដោយអំពើចិត្ត សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំ។

## តើសិទ្ធិរស់រានមានជីវិត មានន័យយ៉ាងណាចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

សិទ្ធិរស់រានមានជីវិតមានន័យថា រាជរដ្ឋាភិបាលនៃប្រទេសរបស់អ្នក មិនអាចយកសិទ្ធិរស់រានមានជីវិតរបស់អ្នកពីអ្នកបានទេ។ រដ្ឋក៏មានភារកិច្ចចាត់វិធានការ ដើម្បីការពារជីវិតរបស់អ្នកផងដែរ។ នេះមានន័យថារដ្ឋាភិបាលនៃប្រទេសរបស់អ្នកត្រូវចាត់វិធានការដើម្បីបញ្ចប់ជំងឺ និងដើម្បីធានាការទទួលបានសេវាថែទាំ ដោយធ្វើការអនុវត្តយុទ្ធសាស្ត្របញ្ចប់ជំងឺរបេងដោយផ្អាកលើការគោរពសិទ្ធិមនុស្ស។

## តើសិទ្ធិទទួលបានសេវាសុខភាព មានន័យយ៉ាងណាចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

សិទ្ធិទទួលបានសេវាសុខភាពរួមបញ្ចូលផ្នែកសំខាន់ចំនួនពីរ។ ផ្នែកដំបូងគឺសេវាថែទាំសុខភាព និងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសមួយ។ សិទ្ធិទទួលបានសេវាសុខភាពមានន័យថា គឺការទទួលបានការថែទាំសុខភាពជាចាំបាច់។ សំរាប់ជំងឺរបេងបានន័យថា ប្រព័ន្ធថែទាំសុខភាពដែលមានកន្លែងផ្តល់សេវាបង្ការជំងឺរបេង សេវាធ្វើរោគ វិនិច្ឆ័យ និងសេវាថែទាំ

ដែលមានបរិក្ខារសំភារៈ សំរាប់ការធ្វើតេស្ត និងការគ្រឿងផ្គត់ផ្គង់នូវឱសថសំរាប់ព្យបាល ដោយគិតបន្ថែមទាំងការផ្តល់សេវាកម្ម និងកម្មវិធីនានា ជាពិសេសការមានថវិកាគ្រប់គ្រាន់សម្រាប់ផ្តល់ជូនបុគ្គលិកថៃទាំសេវាសុខភាព ក៏ដូចជាកម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺរបេងទាំងមូល។ មានន័យថាការផ្តល់សេវាថៃទាំសុខភាព គឺអាចទទួលបានគ្រប់ៗគ្នា ហើយពួកគេមិនត្រូវបានបដិសេធ (ឬដែលហៅថាការមិនរើសអើង) ។ អ្នកក៏គួរតែអាចទៅមណ្ឌលសុខភាព ដែលត្រូវបានបំពាក់គ្រឿងសម្ភារគ្រប់គ្រាន់សំរាប់ព្យាបាលជំងឺរបេង ដែលឧទាហរណ៍ រួមមានស្ថានីយ៍ដែលផ្តល់សេវាថៃទាំដែលមានក្នុងតំបន់ ឬបើចាំបាច់អ្នកផ្តល់សេវាថៃទាំសុខភាពអាចនឹងទៅរកអ្នកផ្ទាល់។ អ្នកគួរតែមានលទ្ធភាពបង់ ថ្លៃសេវាថៃទាំសុខភាព និងថ្លៃការព្យាបាលដោយឱសថរបស់អ្នក។ ហើយអ្នកត្រូវតែទទួលបានព័ត៌មានអំពីជម្រើសនៃការថៃទាំសុខភាពដែលពាក់ពន្ធ័នឹងជំងឺរបេង និងចំណេះទូទៅពីជំងឺនេះ។ សេវាថៃទាំសុខភាពត្រូវមានលក្ខណសមស្រប និងទទួលយកបាន នេះមានន័យថា សេវាថៃទាំសុខភាពត្រូវលក្ខណៈសមស្របទៅនឹងវប្បធម៌ប្រពៃណីរបស់មូលដ្ឋាន ដោយការគោរពក្រមសីលធម៌ និងដោយមានការយកចិត្តទុកដាក់ទៅលើភេទ និងវ័យរបស់អ្នកដែលមានជំងឺរបេង។ សេវាថៃទាំសុខភាពត្រូវតែមានគុណភាពល្អ ដែលមានន័យថា អន្តរាគមន៍នានារបស់វិស័យសុខាភិបាលសម្រាប់ជំងឺរបេង ត្រូវតែឈរលើវិទ្យាសាស្រ្តជាមូលដ្ឋាន ហើយមានលក្ខណៈត្រឹមត្រូវតាមបែបវេជ្ជសាស្រ្ត និងមានឱសថព្យបាលប្រកបដោយគុណភាពខ្ពស់។

“ **ការធ្វើឲ្យមាន ការធ្វើឲ្យទទួលបាន ការដែលអាចទទួលយកបាន និងគុណភាព**" គឺជាផ្នែកនៃសិទ្ធិទទួលបានសេវាសុខភាព ដែលជារឿយៗត្រូវបានគេហៅកាត់ថា AAAQ ។

ផ្នែកទីពីរនៃសិទ្ធិទទួលបានសេវាសុខភាព គឺរាប់បញ្ចូលកត្តាកំណត់នានានៃផ្នែកសុខភាព។ ទាំងក្នុងនោះរួមមាន សិទ្ធិមនុស្សជាច្រើនដែលពាក់ព័ន្ធនឹងសុខភាពរបស់អ្នក។ ជាឧទាហរណ៍ សិទ្ធិក្នុងការទទួលបានស្បៀង ទឹកស្អាត និងមានសុវត្ថិភាព និងអនាម័យគ្រប់គ្រាន់ ផ្ទះសំបែងរស់នៅគ្រប់គ្រាន់ លក្ខខណ្ឌនៃកន្លែងធ្វើការដែលប្រកបដោយសុខភាព និងការទទួលបានការអប់រំពីសុខភាព។ សិទ្ធិទាំងនេះមានសារៈសំខាន់ចំពោះការបង្ការ និងព្យាបាលជំងឺរបេង។ នោះមានន័យថា អ្នកគួរទទួលបានការគាំទ្រផ្នែកអាហារូបត្ថម្ភបន្ថែម លើការទទួលបានឱសថក្នុងកំឡុងពេលព្យាបាលជំងឺរបេងរបស់អ្នក ប្រសិនបើវាអាចជួយដល់អ្នកក្នុងការព្យាបាល។ ឬថាអ្នកអាចត្រូវការ ការគាំទ្របន្ថែមផ្សេងទៀតក្នុងកំឡុងពេល ឬក្រោយពេលអ្នកបានបញ្ចប់ការព្យាបាល ប្រសិនបើជំងឺរបេងបានផ្លាស់ប្តូរសមត្ថភាពរបស់អ្នកក្នុងការរស់នៅ និងការពារសុខភាពរបស់អ្នក។

រដ្ឋាភិបាលរបស់អ្នកក៏ត្រូវផ្តល់ឱសថសារវ័ន្ត។ នេះគឺជា "កាតព្វកិច្ចស្នូល" ដែលស្ថិតនៅក្រោមសិទ្ធិទទួលបានសេវាសុខភាព។ នេះមានន័យថាការផ្តល់ឱសថសារវ័ន្ត គឺជាអ្វីមួយដែលសំខាន់បំផុតសម្រាប់រដ្ឋាភិបាលដែលអាចនិងត្រូវធ្វើដើម្បីគោរព ការពារ និងឆ្លើយតបទៅនឹងសិទ្ធិទទួលបានសុខភាព។ អង្គការសុខភាពពិភពលោក មានតារាងគំរូនៃឱសថសារវ័ន្តដែលមានរាយបញ្ជីឱសថរបេងសំខាន់ៗពាក់ព័ន្ធនឹងជំងឺរបេងទាំងអស់នៅក្នុងផ្នែកទី ៦.២.៤ នៃកំណែទី ១៩ របស់ខ្លួន។

## តើសិទ្ធិមិនត្រូវបានគេរើសអើង មានន័យយ៉ាងដូចម្ដេចចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

ស្ថានភាពសុខភាពរបស់អ្នកមិនគួរត្រូវបានគេប្រើជាហេតុផលដើម្បីធ្វើទៅលើអ្នក គ្រួសារអ្នក ឬអ្នកដែលមើលថែអ្នកខុសពីអ្នកដទៃឡើយ។ នេះមានន័យថា អ្នកមិនអាចត្រូវបានបណ្ដេញចេញពីការងារ បដិសេធការចូលទៅក្នុងសាលា បដិសេធការស្នាក់នៅ ឬដែលត្រូវបានគេធ្វើទៅលើ ដោយមិនគោរពតាមគោលការណ៍នៃកន្លែងផ្ដល់សេវាថែទាំសុខភាព ក៏ព្រោះតែអ្នកមានជំងឺរបេងនោះឡើយ។ ប្រសិនបើអ្នកជាសមាជិកនៃក្រុមងាយរងគ្រោះ ឧទាហរណ៍ អ្នកផ្ទុកមេរោគអេដស៍ អ្នកប្រើប្រាស់ថ្នាំញៀនខុសច្បាប់ អ្នកចំណាកស្រុក ឬអ្នកជាប់ពន្ធនាគារ អ្នកមិនអាចត្រូវបានគេរើសអើងនៅពេលអ្នកព្យាយាមស្វែងរកការទទួលសេវាជំងឺរបេងនោះទេ។

## តើសិទ្ធិទទួលបានសេរីភាព សិទ្ធិក្នុងការធ្វើដំណើរ និងសេរីភាពពីការឃុំខ្លួនតាមអំពើចិត្ត មានន័យយ៉ាងដូចម្ដេចចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

សិទ្ធិទាំងនេះ ធានាថាអ្នកមិនអាចជាប់ពន្ធនាគារ ត្រូវបានគេឃុំខ្លួន ឬត្រូវបានបង្អាក់ពីការធ្វើដំណើរដោយមិនមានកិច្ចដំណើរការនីតិវិធីច្បាប់នោះទេ។ ការឃាត់ខ្លួន ឬការចាប់ខ្លួនត្រូវធ្វើឡើងទៅតាមច្បាប់។ នេះជារឿងសំខាន់សម្រាប់ជំងឺរបេងនៅពេលយើងគិតថា តើការព្យាបាលគួរត្រូវដាក់ឲ្យនៅដាច់ដោយឡែកពីគេ។ ការព្យាបាលដែលដាក់ឲ្យនៅដាច់ដោយឡែកពីគេ សំរាប់ជំងឺរបេង ត្រូវបានគេចាត់ទុកថាជាការចាំបាច់បំផុត ដើម្បីការពារអ្នកដទៃអំពីការឆ្លងជំងឺរបេងនេះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួរតែអាចមានជម្រើសក្នុងការដាក់ឲ្យនៅដាច់ដោយឡែក ដោយមានលក្ខណៈមិនសូវរឹតបន្តឹងតាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍ ការដាក់ឲ្យនៅដាច់ដោយឡែក ដោយគ្រាន់តែពាក់ម៉ាសការពាររហូតដល់អ្នកព្យាបាលជំងឺរបេង បានជាសះស្បើយ ឬក៏ថានឹងមិនឆ្លងទៅអ្នកដទៃ។ អ្នកមិនគួរត្រូវគេបានស្នើសុំឱ្យស្នាក់នៅមន្ទីរពេទ្យទេ ប្រសិនបើការពាក់ម៉ាសនោះមានលក្ខណៈគ្រប់គ្រាន់ហើយ។

នៅក្នុងស្ថានភាពដ៏កម្រខ្លះ រដ្ឋាភិបាលរបស់អ្នក អាចតម្រូវឱ្យអ្នកនៅដាច់ដោយឡែកពីគេ បើទោះបីអ្នកមិនយល់ស្របក៏ដោយ (ការដាក់ឲ្យនៅដាច់ដោយឡែកដោយមិនមានការស្ម័គ្រចិត្ត)។ នេះអាចកើតឡើងបាន លុះត្រាតែជំងឺរបេងរបស់អ្នកមានការឆ្លងយ៉ាងសកម្ម ហើយប្រសិនបើអ្នកបដិសេធមិនប្រើឱសថរបេង ឬអនុវត្តតាមវិធានការគ្រប់គ្រងការឆ្លង និងប្រសិនបើមានហានិភ័យពិតប្រាកដ នៃការរីករាលដាលជំងឺរបេងទៅអ្នកដទៃ។ ការដាក់ឲ្យនៅដាច់ដោយឡែកដោយមិនមានការស្ម័គ្រចិត្តមិនគួរត្រូវធ្វើជាប្រចាំនោះឡើយ ហើយគួរត្រូវបានប្រើ ប្រសិនបើវិធានការដទៃផ្សេងទៀតទាំងអស់រួមមាន ការប្រឹក្សាយោបល់ជាច្រើន ត្រូវបានគេព្យាយាម ហើយទទួលបរាជ័យ។ ការដាក់ឲ្យនៅដាច់ដោយឡែកដោយមិនមានការស្ម័គ្រចិត្ត ត្រូវតែផ្អែកទៅលើច្បាប់ ឬគោលនយោបាយដែលមានស្រាប់ ហើយគួរមានការត្រួតពិនិត្យពីខាងក្រៅយ៉ាងជាប់លាប់។ សំរាប់អ្នក ដែលជាអ្នករងផលប៉ះពាល់ដោយជំងឺរបេង ក៏មានសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍នៅលើសេចក្ដីសំរេចដែលដាក់ឲ្យនៅដាច់ដោយឡែកផងដែរ។

អ្នកមិនគួរត្រូវបានគេដាក់ឲ្យនៅដាច់ដោយឡែកនៅក្នុងបរិយាកាសដែលមិនមានឱសថព្យាបាល ដូចជានៅពន្ធនាគារជាដើម។ ដូចគ្នានេះផងដែរ អ្នកគួរត្រូវបានផ្តល់ការព្យាបាលជំងឺរបេង និងតម្រូវការចាំបាច់ជាមូលដ្ឋានរួមទាំងម្ហូបអាហារ ទឹក និងឱកាសដើម្បីទំនាក់ទំនងជាមួយក្រុមគ្រួសារ។ ការដាក់ឲ្យនៅដាច់ដោយឡែកគួរតែធ្វើក្នុងលក្ខណៈខ្លីតាមដែលអាចធ្វើទៅបាន មានន័យថា ការធ្វើបែបនេះអាចធ្វើដូច្នេះបាន ដរាបណាអ្នកជំងឺរបេងអាចឆ្លង ហើយបង្ហាញពីហានិភ័យពិប្រាកដដល់អ្នកដទៃ។ ការដាក់ឲ្យនៅដាច់ដោយឡែក មិនគួរជាលក្ខខណ្ឌនៃការផ្តល់ឲ្យនៃឱសថថ្មីនោះឡើយ។

## តើសិទ្ធិឯកជន មានន័យយ៉ាងណាសំរាប់អ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង ?

សិទ្ធិឯកជន មានន័យថា ស្ថានភាពសុខភាពរបស់អ្នករួមទាំង ស្ថានភាពរបស់អ្នកមាន ឬគ្មានជំងឺរបេង និងព័ត៌មានផ្ទាល់ខ្លួន មិនគួរត្រូវបានចែកចាយជាមួយនរណាម្នាក់ឡើយ លុះត្រាតែអ្នកអនុញ្ញាត ឬវាជាការចាំបាច់ដើម្បីការពារសុខភាពរបស់អ្នកដទៃ។ នៅកន្លែងភាគច្រើន ជំងឺរបេងគឺស្ថិតក្នុង "លក្ខខណ្ឌដែលតំរូវឲ្យមានការជូនដំណឹង" ។ នេះមានន័យថា អាជ្ញាធរសុខាភិបាលត្រូវរាយការណ៍ករណីជំងឺរបេងទៅក្រសួងសុខាភិបាល។ បើទោះជាយ៉ាងនេះក្តី ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក (ដូចជាឈ្មោះរបស់អ្នក) គឺមិនគួរត្រូវបានគេចែកចាយនោះទេ។ ប្រសិនបើអ្នកមានអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងមួយទៀត ពួកគេអាចចែករំលែកព័ត៌មានអំពីសុខភាពរបស់អ្នកជាមួយគ្នាទៅវិញទៅមក ដើម្បីផ្តល់ការថែទាំសុខភាពប្រកបដោយគុណភាពល្អ។ ប្រសិនបើជំងឺរបេងរបស់អ្នកស្ថិតក្នុងស្ថានភាពឆ្លង ហើយមនុស្សដែលអ្នកទាក់ទងជាមួយនឹងមានហានិភ័យខ្ពស់នៃការឆ្លងជំងឺរបេង អ្នកគួរតែផ្តល់ដំណឹងដល់ពួកគេ លើកទឹកចិត្តពួកគេឲ្យធ្វើតេស្ត និងចាត់វិធានការការពារប្រឆាំងនឹងការរីករាលដាលនៃជំងឺរបេងនេះ។ ឧទាហរណ៍ អ្នកអាចជ្រើសរើសពាក់ម៉ាសជាការចាំបាច់ ក្នុងការរស់នៅជាមួយគ្រួសារ។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចសុំឱ្យអ្នកដែលនៅជិតជាមួយអ្នកដឹងថាពួកគេត្រូវការការធ្វើតេស្ត ដោយមិនចាំបាច់គិតថានរណាស្ថិតក្នុងទំនាក់ទំនងជិតស្និតនោះទេ។ ប្រសិនបើអ្នកបដិសេធ ឬមិនអាចធ្វើដូចនេះបាន អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចជូនដំណឹងដល់អ្នកទាំងនោះថា ជំងឺរបេងរបស់អ្នកគឺមានលក្ខណៈឆ្លង ហើយ ពួកគេអាចចាត់វិធានការដើម្បីការពារខ្លួនឯង។ នៅពេលណាដែលមិនមានហានិភ័យកើតឡើងដល់អ្នកដទៃក្នុងការការឆ្លងនោះ មានន័យថា អ្នកមានការការពារពេញលេញ នៃសិទ្ធិឯកជនរបស់អ្នក ។

## តើសិទ្ធិទទួលបានវិទ្យាសាស្រ្ត មានអត្ថន័យយ៉ាងណាចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង ?

សិទ្ធិទទួលបានវិទ្យាសាស្រ្តមានន័យថា មនុស្សគ្រប់រូប គួរតែអាចទទួលបានផលប្រយោជន៍ពីការរកឃើញវិទ្យាសាស្រ្តថ្មីដោយគិតទាំងការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងវិធីសាស្រ្តព្យាបាលថ្មីៗ។ រដ្ឋាភិបាលរបស់អ្នកគួរតែចាត់វិធានការធ្វើឱសថថ្មី វិធីថ្មីៗដើម្បីទប់ស្កាត់ជំងឺរបេង និងវិធីថ្មីនៃការធ្វើតេស្តរកជំងឺរបេងដែលមាននៅក្នុងប្រទេសរបស់អ្នក។ រដ្ឋាភិបាលក៏មានកាតព្វកិច្ចដើម្បីគាំទ្រ និងពន្លឿនវិទ្យាសាស្រ្តផងដែរ។ ឧទាហរណ៍ នោះមានន័យថា រដ្ឋាភិបាលរបស់អ្នកគួរតែផ្តល់

ថវិកាសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងគាំទ្រស្ថាប័នស្រាវជ្រាវសាធារណៈ។ នៅពេលរដ្ឋាភិបាលរបស់អ្នកផ្តល់ថវិកា ឬការលើកទឹកចិត្តផ្សេងទៀតសម្រាប់ការស្រាវជ្រាវទៅឲ្យក្រុមហ៊ុនឯកជន វាក៏គួរតែប្រាកដថាលទ្ធផលនៃការស្រាវជ្រាវនោះនឹងផ្តល់ប្រយោជន៍ដល់អ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេងនៅក្នុងប្រទេសរបស់អ្នក និងមានតំលៃសមរម្យ។ សិទ្ធិទទួលបានវិទ្យាសាស្ត្រ ក៏ត្រូវបានភ្ជាប់ទៅនឹងសិទ្ធិក្នុងការចូលរួមផងដែរ។ សហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង គួរតែត្រូវបានរាប់បញ្ចូលក្នុងដំណើរនៃការសិក្សាស្រាវជ្រាវ ដែលមានការចូលរួមពេញលេញ និងដោយមានការគោរព ការចូលរួមរបស់ពួកគេ។

## តើសិទ្ធិក្នុងការទទួលព័ត៌មានមានន័យយ៉ាងណាចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

ក្នុងចំនោមរឿងដទៃផ្សេងទៀត សិទ្ធិក្នុងការទទួលព័ត៌មានមានន័យថា អ្នកនិង ប្រសិនបើអ្នកចង់ អ្នកដែលពាក់ព័ន្ធក្នុងការផ្តល់ថែទាំរបស់អ្នក ដូចជាសាច់ញាតិ ឬមិត្តភក្តិ គួរត្រូវបានគេប្រាប់អំពីជម្រើសនានា សម្រាប់ការព្យាបាលវេជ្ជសាស្ត្ររបស់អ្នក។ វាក៏មានន័យថាអ្នក និងសហគមន៍របស់អ្នក គួរតែត្រូវបានគេផ្តល់ព័ត៌មានត្រឹមត្រូវអំពីរបៀបដែលជំងឺរបេងរាតត្បាត វិធីបង្ការការរាតត្បាតរបស់វា និងបានដឹងអំពីរយៈពេលដែលអ្នកជំងឺរបេងបានចំលងទៅអ្នកដទៃ។ អ្នកក៏គួរទទួលបានផងដែរនៃការប្រឹក្សា និងការពន្យល់នានា ដែលអ្នកត្រូវយល់ស្រប(យល់ព្រម) ចំពោះអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រ។ នេះក៏មានន័យផងដែរថា អ្នកមានសិទ្ធិត្រូវដឹងអំពីឈ្មោះ និងកំរិតនៃការប្រើថ្នាំ ឬការធ្វើអន្តរាគមន៍ណាមួយដែលវេជ្ជបណ្ឌិតរបស់អ្នកចង់ឱ្យអ្នកធ្វើ។ អ្នកក៏ត្រូវដឹងពីរយៈពេលនៃការព្យាបាល និងក៏បានដឹងពីផលរំខានដែលអាចកើតមាន និងរបៀបដទៃផ្សេងទៀត ដែលការអន្តរាគមន៍អាចមានផលប៉ះពាល់ដល់សុខភាព ឬជីវិតរបស់អ្នក។ នេះត្រូវបានគេហៅថា **ចំណេះដឹងផ្នែកការព្យាបាល។** សិទ្ធិទទួលព័ត៌មានក៏មានន័យផងដែរថា អ្នកគួរទទួលបានច្បាប់ចម្លងនៃការព្យាបាលរបស់អ្នក ប្រសិនបើអ្នកចង់បាន។

## តើសិទ្ធិទទួលបានការព្រមព្រៀងយល់ព្រម មានន័យយ៉ាងណាសម្រាប់អ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

សិទ្ធិទទួលបានការព្រមព្រៀងយល់ព្រម ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយសិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិក្នុងការចូលរួម។ ការព្រមព្រៀងយល់ព្រមមានន័យថា អ្នកត្រូវបានយល់ព្រមចំពោះការធ្វើអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រណាមួយមុននឹងវាកើតឡើង គឺថាដំបូង អ្នកត្រូវតែបានទទួលបានព័ត៌មានពេញលេញអំពីហានិភ័យ និងអត្ថប្រយោជន៍នៃការធ្វើអន្តរាគមន៍។ ព័ត៌មានដែលអ្នកត្រូវមាន គឺជាមូលដ្ឋានសម្រាប់ការធ្វើសម្រេចចិត្តរបស់អ្នក ថាតើអនុញ្ញាតឱ្យមានអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រ ឬក៏យ៉ាងណា (ឧទាហរណ៍ ថ្នាំព្យាបាលជំងឺរបេងជាក់លាក់ណាមួយ ឬថាតើអ្នកចង់ប្រើការព្យាបាលបង្ការដែរឬទេ) ។ នេះមានន័យថា អ្នកគួរតែមានការផ្តល់ប្រឹក្សា មុនពេលអ្នកធ្វើការសម្រេចចិត្ត ហើយអ្នកត្រូវបានគេផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីគិតអំពីសំណួរ និងទទួលចម្លើយចំពោះសំណួររបស់អ្នក។ ការព្យាបាលដោយបង្ខំចំពោះជំងឺរបេងមិនត្រូវបានអនុញ្ញាតជាដាច់ខាត។

## តើសិទ្ធិក្នុងការចូលរួមមានន័យយ៉ាងដូចម្តេចចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង ?

សិទ្ធិក្នុងការចូលរួមមានន័យថា អ្នកដែលជាអ្នកមានជំងឺរបេង គួរត្រូវចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់អ្នក។ក្នុងនោះរួមមាន ការព្យាបាលដោយវេជ្ជសាស្ត្ររបស់អ្នក។ ទោះយ៉ាងណាក៏ដោយ វាក៏គួរតែមានការអនុវត្តទូលំទូលាយផងដែរ។ អ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង មានសិទ្ធិចូលរួមក្នុងការសំរេចចិត្តផ្នែកគោលនយោបាយសុខភាពពីថ្នាក់ជាតិចុះទៅថ្នាក់សហគមន៍។ ឧទាហរណ៍ នេះអាចមានន័យថា អាជ្ញាធរសុខាភិបាលស្វែងរកការបញ្ចូលអង្គការដែលតំណាងឱ្យមនុស្សដែលមានជំងឺរបេង នៅពេលវាយតម្លៃកម្មវិធីជំងឺរបេង ឬក៏ឲ្យសហគមន៍ចូលរួមនៅក្នុងការបង្កើតវិធីសាស្ត្រសម្រាប់ការថែទាំ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់មនុស្ស ឬអ្នកជំងឺ។




*Photo Credit: David Harrison for Treatment Action Campaign*

## តើសេរីភាពនៃការបង្កើតសមាគម និងសេរីភាពនៃការជួបប្រជុំមានន័យយ៉ាងណាចំពោះអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេង?

សិទ្ធិក្នុងការចូលរួមគឺជាមូលហេតុមួយដែលសេរីភាពនៃការបង្កើតសមាគម និងសេរីភាពនៃការជួបប្រជុំដើរតួនាទីសំខាន់ក្នុងកម្មវិធីជំងឺរបេង។ សេរីភាពនៃការជួបប្រជុំ អនុញ្ញាតឱ្យក្រុមមនុស្សជួបជុំគ្នា ឧទាហរណ៍ ដើម្បីពិភាក្សាបញ្ហាសុខភាពទៅក្នុងសហគមន៍។ សេរីភាពបង្កើតសមាគម អនុញ្ញាតឱ្យអ្នក និងមនុស្សដទៃទៀតដែលរងផលប៉ះពាល់ដោយជំងឺរបេងបង្កើត និងចុះឈ្មោះអង្គការ (ឧទាហរណ៍ ក្រុមសហគមន៍ដែលផ្ដល់ការគាំទ្រដល់ប្រជាជនដែលរងផលប៉ះពាល់ដោយជំងឺ) ឬដើម្បីតស៊ូមតិសម្រាប់សិទ្ធិរបស់អ្នកជំងឺរបេង។

## តើការថែទាំដោយយកអ្នកជំងឺជាគោល គឺជាអ្វី?

ការថែទាំដោយយកអ្នកជំងឺជាគោល មានន័យថា អ្វីគ្រប់យ៉ាងដែលត្រូវធ្វើជាមួយ ការបង្ការជំងឺរបេង ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលគួរតែពិចារណា លើតម្រូវការរបស់មនុស្សទាំងមូល។ នេះរួមបញ្ចូលការគោរពសិទ្ធិរបស់មនុស្សម្នាក់ៗ និងការគិតអំពីសង្គម និងកត្តាសេដ្ឋកិច្ច ដោយមិនគិតត្រឹមតែអំពីព័ត៌មានវេជ្ជសាស្ត្រប៉ុណ្ណោះទេ។ ផែនការព្យាបាលរបស់អ្នកគួរតែត្រូវបានធ្វើឡើង ដើម្បីដោះស្រាយស្ថានភាពជាក់លាក់របស់អ្នក។ វាគួរតែជាការការពារសិទ្ធិរបស់អ្នក មិនមែនរំលោភបំពានលើវាទេ។ជំងឺរបេងប៉ះពាល់មនុស្សច្រើនជាងមួយនាក់។ នោះហើយជាមូលហេតុដែលយើងគិតអំពីការថែទាំគ្រួសារ និងសហគមន៍ជាគោលផងដែរ។មនុស្ស ដែលជួយថែទាំក្រុមគ្រួសារ ឬសមាជិកសហគមន៍ដែលរស់នៅជាមួយនឹងជំងឺរបេង ត្រូវទទួលបានព័ត៌មានអំពីសេវាបង្ការ សេវាធ្វើរោគវិនិច្ឆ័យ និងសេវាព្យាបាលដូចគ្នាទៅនឹងមនុស្សដែលមានជំងឺរបេងដែរ។

## តើនេះមានន័យយ៉ាងដូចម្ដេច សម្រាប់គ្រួសារនិងសហគមន៍?

គ្រួសារ និងសហគមន៍ ដើរតួនាទីសំខាន់ក្នុងការបង្ការជំងឺរបេង ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល។ នោះហើយជាមូលហេតុដែលអង្គការនៅតាមសហគមន៍ (CBOs) និងក្រុមគាំទ្រ មានសារៈសំខាន់ខ្លាំងណាស់។ អ្នកមានសិទ្ធិ នៃសេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពនៃការជួបប្រជុំ។ នេះមានន័យថាអ្នក អ្នកជំងឺដទៃទៀត និងសហគមន៍របស់អ្នកមានសិទ្ធិជួបប្រជុំដើម្បីចែករំលែកព័ត៌មាន។ អ្នកមានសិទ្ធិបង្កើតអង្គការ ដែលគាំទ្រមនុស្សមានជំងឺរបេង អ្នកផ្ដល់ការថែទាំរបស់ពួកគេ និងសហគមន៍របស់ពួកគេ។

## តើខ្ញុំគួរធ្វើយ៉ាងណា ប្រសិនបើសិទ្ធិរបស់ខ្ញុំត្រូវបានគេរំលោភបំពាន?

អ្នកមានសិទ្ធិធ្វើពាក្យបណ្តឹង។ អាជ្ញាធរសុខាភិបាលគួរតែមានកន្លែងសម្រាប់អ្នកដើម្បីបង្កើតពាក្យបណ្តឹង។ អ្នកក៏មានសិទ្ធិទទួលបានការឆ្លើយតបផងដែរ។ ប្រសិនបើអ្នកមិនទទួលបានការឆ្លើយតប ឬប្រសិនបើអ្នកទទួលបានការឆ្លើយតបដែលមិនឆ្លើយតបនឹងកង្វល់ ឬតម្រូវការរបស់អ្នក អ្នកអាចមានសិទ្ធិយកពាក្យបណ្តឹងនោះទៅកាន់តុលាការ។នេះអាស្រ័យលើច្បាប់របស់ប្រទេសអ្នក ហើយអ្នកគួរទាក់ទងជំនួយផ្នែកច្បាប់ ឬអ្នកអនុវត្តវិជ្ជាជីវៈផ្នែកច្បាប់ពីអង្គការ។មានអង្គការដែលមានឯកទេស ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សជុំវិញសិទ្ធិទទួលបានសុខភាព។ នោះរួមបញ្ចូលទាំងសិទ្ធិរបស់អ្នកក្នុងការទទួលបានការព្យាបាល និងសិទ្ធិផ្សេងៗដែលមានចែងក្នុងផ្នែកទី ១ "សិទ្ធិមនុស្ស និងជំងឺរបេង"។

ប្រទេសជាច្រើនមានការិយាល័យសិទ្ធិមនុស្ស ឬស្ថាប័នសិទ្ធិមនុស្សជាតិ។ ទាំងនេះគឺជាក្រុមឯករាជ្យដែលតាមដានការពារ និងស្តារសិទ្ធិមនុស្ស ហើយអាចទទួលបានពាក្យបណ្តឹងពីបុគ្គលម្នាក់ៗអំពីការរំលោភសិទ្ធិមនុស្ស។ អ្នកអាចរកមើលថា តើប្រទេសរបស់អ្នកមានស្ថាប័នសិទ្ធិមនុស្សជាតិ ឬទេដោយមើលនៅទីនេះ https://nhri.ohchr.org/EN/Pages/default.aspx ។ នៅក្នុងស្ថានភាពមួយចំនួនវាអាចនឹងលឿនក្នុងការទៅដល់អង្គការតស៊ូមតិអ្នកជំងឺក្នុងស្រុកមួយប្រសិនបើអ្នកគិតថាសិទ្ធិរបស់អ្នកត្រូវបានគេរំលោភបំពាន និងចង់ទទួលព័ត៌មានអំពីជម្រើសរបស់អ្នក។

# ដឹងអំពីសិទ្ធិរបស់អ្នក

## ការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺរបេង

## សិទ្ធិរបស់អ្នក និងការបង្ការជំងឺរបេង

ដោយ **GISA DANG**

កែសំរួលដោយ Tsira Chakhaia, Brian Citro, Vivian Cox, Mike Frick, Jennifer Furin, Erica Lessem, Alexander William Mbuya, Lindsay McKenna, John Mdluli, Jane Rahedi Ong’ang’o, Hadija H. Semvua, and Zani de Wit



### តើការព្យាបាលបង្ការជំងឺរបេងគឺជាអ្វី ?

អ្នកអាចឆ្លងរោគរបេង ប្រសិនបើអ្នកដកដង្ហើមចេញចូលក្នុងខ្យល់ ហើយមាននរណាម្នាក់ដែលមានជំងឺរបេង និងក្អក។ ការឆ្លងមេរោគរបេងបែបនេះ អាចត្រូវបានគេចាត់ទុកជាការឆ្លងជំងឺរបេងគ្មានរោគសញ្ញា ឬ LTBI ។ ការឆ្លងមេរោគរបេងមានន័យថា អ្នកមានបាក់តេរីរបេងនៅក្នុងរាងកាយរបស់អ្នក ប៉ុន្តែវាមិនធ្វើឱ្យអ្នកឈឺទេ។ នេះមានន័យថា អ្នកមិនអាចឆ្លងមេរោគរបេងទៅអ្នកដទៃ។ ក្នុងករណីជាច្រើន រាងកាយរបស់អ្នកអាចរក្សាការឆ្លងមេរោគរបេងនេះឱ្យស្ថិតនៅក្រោមការគ្រប់គ្រង ហើយអ្នកមិនមានរោគសញ្ញាណាមួយ។ ប៉ុន្តែក្នុងករណីមួយ ចំនួនជាពិសេសប្រសិនបើប្រព័ន្ធភាពស៊ាំមិនដំណើរការល្អ មេរោគរបេងនៅក្នុងខ្លួនអាចមានចំនួនច្រើននឹងធ្វើឱ្យអ្នកឈឺនៅពេលអនាគត ដែលគេហៅថាជំងឺរបេងសកម្ម។

### តើខ្ញុំដឹងថាខ្ញុំឆ្លងជំងឺរបេងដោយរបៀបណា ?

មានតេស្តពីរប្រភេទសម្រាប់ពិនិត្យមើលការឆ្លងមេរោគរបេង។ មួយត្រូវបានគេហៅថា ការធ្វើតេស្តតាមស្បែក ឬ TST ។ វាពាក់ព័ន្ធនឹងការចាក់ប្រូតេអ៊ីនគ្មានប្រតិកម្មតិចតួចទៅក្នុងស្បែករបស់អ្នក( ជាទូទៅនៅក្នុងដើមដៃរបស់អ្នក) ហើយសុំឱ្យអ្នកត្រលប់មកវិញមួយឬពីរថ្ងៃក្រោយ ដើម្បីដឹងថាស្បែករបស់អ្នកមានប្រតិកម្មឬទេ បើមាននោះមានន័យថាអ្នកឆ្លងមេរោគរបេង។ ប្រភេទនៃការធ្វើតេស្តមួយផ្សេងទៀតត្រូវបានគេហៅថាការធ្វើតេស្ត interferon gamma release assay ឬ IGRA ។ ការធ្វើតេស្ត IGRA គឺពិនិត្យយកឈាមបន្តិចបន្តួចរបស់អ្នកសម្រាប់ពិនិត្យរោគសញ្ញានៃការឆ្លងមេរោគរបេង។ ការធ្វើតេស្តមួយក្នុងចំណោមការធ្វើតេស្តទាំងនេះ អាចមិនចាំបាច់សម្រាប់ការចាប់ផ្តើមការព្យាបាលដោយបង្ការ ប្រសិនបើអ្នកមានហានិភ័យខ្ពស់នៃជំងឺរបេងសកម្ម។ នេះដោយសារតែការធ្វើតេស្តទាំងនេះ មិនមានលក្ខណៈល្អឥតខ្ចោះ។ការធ្វើតេស្តតាមស្បែក អាចមានលទ្ធផលវិជ្ជមាន ចំពោះអ្នកដែលមិនត្រូវបានឆ្លងមេរោគរបេង ប៉ុន្តែបានចាក់វ៉ាក់សាំង BCG ។ ចំពោះមនុស្សមួយចំនួនជាពិសេសអ្នកដែលក្មេងពេក ឬអ្នកដែលប្រព័ន្ធភាពស៊ាំមិនដំណើរការល្អទាំង TST

ឬ IGRA អាចមានលទ្ធផលអវិជ្ជមានបើទោះបីជាមានការឆ្លងមេរោគរបេងក៏ដោយ។មនុស្សដែលមានត្រូវបានប៉ះពាល់ នឹងជំងឺរបេងនៅក្នុងផ្ទះ ឬកន្លែងផ្សេងទៀតរបស់ពួកគេ អាចទទួលបានអត្ថប្រយោជន៍ពីការព្យាបាលដោយបង្ការ និងមានសិទ្ធិពិភាក្សាបញ្ហានេះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេ។

### តើការព្យាបាលដោយថ្នាំបង្ការគឺជាអ្វី?

ការព្យាបាលដោយបង្ការមានន័យថា ជាការលេបថ្នាំបង្ការជំងឺរបេង ដើម្បីការពារអ្នកពីការធ្លាក់ខ្លួនឈឺ។វេជ្ជបណ្ឌិត ឬ គិលានុបដ្ឋាយិការបស់អ្នក អាចណែនាំឱ្យអ្នកប្រើការព្យាបាលបង្ការក្រោយពីធ្វើតេស្តដើម្បីដឹងថាតើអ្នកការឆ្លងមេរោគរបេងឬក្រោយសួរអំពីកត្តាហានិភ័យរបស់អ្នក។ដោយសារការធ្វើតេស្តរករោគវិនិច្ឆ័យជំងឺរបេងគឺមិនសូវល្អទេក្នុងការប្រាប់ថានរណានឹងមានរោគរបេងសកម្មនៅពេលខាងមុខ គ្រូពេទ្យឬ គិលានុបដ្ឋាយិកាអាចផ្តល់ការព្យាបាលដល់អ្នកដោយឈរលើតែកត្តាគ្រោះថ្នាក់។ កត្តាហានិភ័យមួយគឺកំពុងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកដែលមានជំងឺរបេង អ្នកដែល មានទំនាក់ទំនងជាមួយអ្នកជំងឺរបេង គួរត្រូវបានពិនិត្យរកមើលជំងឺរបេង ហើយប្រសិនបើពួកគេមាន ឬមានលទ្ធភាពឆ្លងមេរោគរបេង គួរតែត្រូវបានផ្តល់ការព្យាបាលដោយបង្ការ។កត្តាហានិភ័យមួយទៀតគឺការឆ្លងមេរោគអេដស៍។ជាការពិតអង្គការសុខភាពពិភពលោកណែនាំអ្នកដែលមានមេរោគអេដស៍ ឬក្មេងដែលមានអាយុក្រោម ៥ ឆ្នាំដែលរស់នៅជាមួយអ្នកដែលមានជំងឺរបេងគួរតែត្រូវបានគេផ្តល់ការព្យាបាលដោយបង្ការ(ដរាបណាពួកគេមិនមានជម្ងឺឆ្លង)សូម្បីតែមិនមានការធ្វើតេស្តឆ្លងមេរោគរបេងក៏ដោយ។

មានការព្យាបាលបង្ការខុសៗគ្នាជាច្រើនដែលមានប្រសិទ្ធិភាពនិងមានសុវត្ថិភាព:

- ប្រាំមួយខែ ប្រាំបួនខែ ៣៦ខែ ឬការព្យាបាលពេញមួយជីវិត ដែលហៅថាថ្នាំប្រឆាំងនឹងជំងឺរបេង (isoniazid) ត្រូវលេបជារៀងរាល់ថ្ងៃ។ ចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍ ក៏អាចត្រូវបានផ្តល់ឱ្យថ្នាំ cotrimoxazole ផងដែរដើម្បីការពារស្ថានភាពទាក់ទងនឹងមេរោគអេដស៍ផ្សេងៗទៀត។

- បីខែនៃ isoniazid បូកជាមួយ rifapentine ត្រូវលេបម្តងក្នុងមួយសប្តាហ៍។នេះគឺជាជម្រើសថ្មីបំផុត និងមានមនុស្សច្រើនគិតថាវាងាយស្រួលបំផុត។

- ពី ៣ ទៅ ៤ ខែនៃការលេប isoniazid បូកជាមួយ rifapentine ជាថ្នាំប្រឆាំងនឹងជំងឺរបេងមួយផ្សេងទៀត។

- ពី បី ទៅ បួន ខែនៃការប្រើថ្នាំ Rifampicin ប្រចាំថ្ងៃតែមួយមុខ។

**សូមកត់សម្គាល់**: ប្រសិនបើអ្នកកំពុងប្រើការព្យាបាលដោយបង្ការដែលរួមមាន isoniazid អ្នកក៏គួរតែត្រូវបានគេផ្តល់វីតាមីន B6 (ឬម៉្យាងទៀត គេហៅថា pyridoxine) ដើម្បីបង្ការការខូចខាតដល់សរសៃប្រសាទរបស់អ្នក។ប្រសិនបើអ្នកប្រើថ្នាំប្រឆាំងនឹងមេរោគអេដស៍ (ART) វេជ្ជបណ្ឌិតរបស់អ្នកគួរ តែចេញវេជ្ជបញ្ជាដោយការព្យាបាលការការពារដែល មានការព្យាបាលដោយ rifampicin ឬ rifapentine ព្រោះវាអាចធ្វើអន្តរកម្មជាមួយថ្នាំប្រឆាំងមេរោគអេដស៍ទូទៅ។

## តើការព្យាបាលដោយបង្ការមានប្រសិទ្ធភាពសម្រាប់ជំងឺរបេងដែលស៊ាំនឹងថ្នាំច្រើនមុខឬទេ (MDR-TB)?

ជំងឺរបេងដែលស៊ាំនឹងថ្នាំច្រើនមុខ មានន័យថាសំពាធនៃជំងឺរបេង គឺមានភាពស៊ាំទៅនឹង isoniazid និង rifampicin ដូច្នេះការព្យាបាលដោយបង្ការ ដែលជាជម្រើសដែលបានលើកឡើងខាងលើអាចមិនដំណើរការ។ អង្គការសុខភាពពិភពលោក ថ្មីៗនេះ បានចេញផ្សាយការណែនាំថ្មី ដែលណែនាំការព្យាបាលដោយបង្ការ ដែលអាចពិចារណាសម្រាប់អ្នកដែលរស់នៅជាមួយអ្នកដែលមានជំងឺរបេងដែលស៊ាំនឹងថ្នាំច្រើនមុខ។ មានការសិក្សាជាបន្តបន្ទាប់ជាច្រើន ដើម្បីវាយតម្លៃការព្យាបាលដែលល្អបំផុតសម្រាប់ការឆ្លងមេរោគរបេងដែលស៊ាំនឹងថ្នាំច្រើនមុខ។ អ្នកគួរតែសាកសួរ ប្រសិនបើការសិក្សាកំពុងត្រូវបាន ធ្វើនៅក្នុងតំបន់របស់អ្នក។ក្នុងស្ថានភាពខ្លះការព្យាបាលការឆ្លងមេរោគរបេងដែលស៊ាំនឹងថ្នាំច្រើនមុខដោយប្រើ ឱសថដូចជា levofloxacin ឬ moxifloxacin អាចត្រូវបានផ្តល់ជូនដល់បុគ្គលដែលមានហានិភ័យខ្ពស់។ អ្នកគួរពិភាក្សាពីហានិភ័យ និងអត្ថប្រយោជន៍នៃការទទួលថ្នាំនេះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

## តើនរណា គួរទទួលបានការព្យាបាលដោយថ្នាំបង្ការជំងឺរបេង?

អង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍ថា អ្នកផ្ទុកមេរោគអេដស៍ទាំងអស់ និងកុមារទាំងអស់ដែលមានអាយុក្រោម 5 ដែលរស់នៅជាមួយ ឬមានភាពជិតស្និទ្ធនឹងអ្នកដែលមានជំងឺរបេងត្រូវព្យាបាលការបង្ការ នៅពេលពួកគេមិនមានជំងឺរបេងសកម្ម។នេះគឺដោយសារតែកុមារ និងអ្នកដែលមានផ្ទុកមេរោអេដស៍មានហានិភ័យខ្ពស់ក្នុងការវិវត្តទៅជាជំងឺរបេងបើសិនជាពួកគេត្រូវបានប៉ះពាល់បាក់តេរី។ អង្គការសុខភាពពិភពលោកក៏បានផ្តល់ដំបូន្មានផងដែរថា ការព្យាបាលដោយបង្ការ អាចត្រូវបានផ្តល់ជូនដល់មនុស្សដែលមានអាយុពី ៥ ឆ្នាំឡើងទៅដែលរស់នៅជាមួយអ្នកដែលមានជំងឺរបេង ប្រសិនបើពួកគេរស់នៅក្នុងប្រទេសដែលមានបន្ទុកជំងឺរបេងខ្ពស់ហើយមិនមានជំងឺរបេងសកម្ម។ ដោយសារជំងឺរបេងគឺឆ្លងតាមខ្យល់ នៅពេលដែលនរណាម្នាក់មានទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សដែលមានជំងឺរបេងគឺមាន ហានិភ័យខ្ពស់នៃជំងឺរបេង (ដូចជាធ្វើការនៅក្នុងអណ្តូងរ៉ែជាកន្លែងដែលអ្នកត្រូវបានប៉ះពាល់នឹងធូលីស៊ីលីកាដែលបណ្តាលអោយកើតមានជំងឺឈាមសស៊ីឈាមក្រហម ឬរស់នៅក្នុងគុកដោយពុំមានខ្យល់អាកាសល្អ) គួរមានលទ្ធភាពពិនិត្យរកមើលជំងឺរបេង។

## តើខ្ញុំអាចត្រូវបានគេបង្ខំឱ្យទទួលការព្យាបាលបង្ការជំងឺរបេងឬទេ ?

ការព្យាបាលដោយបង្ការមិនគួរចាត់ទុកជាភាពចាំបាច់ទេ។ អ្នកគួរតែមានជម្រើសក្នុងការទទួលយកវា (ការយល់ព្រម) ឬមិនយល់ព្រម។ អ្នកអាចលើកទឹកចិត្តដល់អ្នកជាទីស្រឡាញ់ដែលមានហានិភ័យឲ្យទៅទទួលការព្យាបាលដោយបង្ការ ប៉ុន្តែវាគឺជាជម្រើសរបស់ពួកគេក្នុងការទទួលយកវា ឬមិនយក។ អ្នកមានសិទ្ធិទទួលព័ត៌មានយ៉ាងពេញលេញអំពីផលប្រយោជន៍ គ្រោះថ្នាក់ និងចំណេះដឹងដែលមានស្រាប់អំពីការព្យាបាលបង្ការរោគរបេង។សម្រាប់កុមារ ឪពុកម្តាយឬអាណាព្យាបាលស្របច្បាប់ ត្រូវផ្តល់ការយល់ព្រមទៅលើនីតិវិធី ឬទៅលើថ្នាំ រួមទាំងការព្យាបាលដោយបង្ការ។ នៅកន្លែងខ្លះច្បាប់មិនអនុញ្ញាតឱ្យកូនៗយល់ព្រមលើការព្យាបាល និងការសម្រេចចិត្តផ្នែកវេជ្ជសាស្ត្រដោយខ្លួនឯងទេ។ ច្បាប់ស្តីពីការយល់ព្រម និងអាយុនៃការយល់ព្រម គឺមានលក្ខណៈខុសៗគ្នាទៅតាមប្រទេស។ នៅប្រទេសជាច្រើន គឺគេកំណត់អាយុ 18 ឆ្នាំ ប៉ុន្តែនៅប្រទេសខ្លះវាមានអាយុតិចឬច្រើនជាងនេះ។

## ខ្ញុំកំពុងថែទាំសមាជិកគ្រួសារដែលមានជំងឺរបេង។ តើខ្ញុំត្រូវដឹងអ្វីខ្លះ ?

ជំងឺរបេងគឺជាជំងឺឆ្លង ប៉ុន្តែសូមចងចាំថា ជំងឺរបេងអាចឆ្លងតាមខ្យល់បាន តែនៅពេលអ្នកដែលមានជំងឺឆ្លងជំងឺរបេង (ហៅថាជំងឺរបេងវិជ្ជមាន) ក្អក កណ្តាស់ ច្រៀង ឬស្រែក។ ជំងឺរបេងមិនឆ្លងដោយការប៉ះ ឈាម មេជីវិតឈ្មោល ឬទឹករំអិលទ្វារមាស ឬតាមរយៈការចែកអាហារចំណី គ្រឿងផ្ទះបាយ ចាន ឬកែវនោះទេ។ ជំងឺរបេងជាទូទៅមិនឆ្លងបន្ទាប់ពីពីរសប្តាហ៍នៃ ការព្យាបាលបានល្អ។ការឆ្លងភាគច្រើនកើតឡើងមុនពេលមាននរណាម្នាក់ទទួលការព្យាបាលដែលមានប្រសិទ្ធភាព។ ភ្លាមៗបន្ទាប់ពីការព្យាបាលដែលមានប្រសិទ្ធិភាពបានចាប់ផ្តើម នោះហានិភ័យនៃការឆ្លងបានធ្លាក់ចុះយ៉ាងខ្លាំង។

យើងដឹងថាមធ្យោបាយដ៏សំខាន់បំផុតដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺរបេង គឺត្រូវធ្វើរោគវិនិច្ឆ័យឱ្យបានយ៉ាងឆាប់ដល់មនុស្សគ្រប់រូបដែលមានជំងឺ និងផ្តល់ឱ្យពួកគេនូវការចាប់ផ្តើមព្យាបាលប្រកបដោយប្រសិទ្ធភាព ហើយគាំទ្រពួកគេឱ្យទទួលបាននូវការព្យាបាលឱ្យបានរហូតដល់បញ្ចប់ និងជាសះស្បើយ។

ប្រសិនបើអ្នកមានការទាក់ទងជិតស្និទ្ធជាមួយអ្នកដែលមានជំងឺរបេង ដែលនៅតែឆ្លងមេរោគ សូមព្យាយាមស្នាក់នៅក្នុងតំបន់ដែលមានខ្យល់អាកាសល្អប្រសើរ មានពន្លឺព្រះអាទិត្យឬពន្លឺកាំរស្មីUV នៅពេលអ្នកនៅជាមួយអ្នកជំងឺរបេង។ អ្នកគួរតែពិនិត្យរកមើលជំងឺរបេងជាទៀងទាត់ដោយយកចិត្តទុកដាក់លើរោគសញ្ញានៃជំងឺរបេង។ ប្រសិនបើ អ្នកមិនមានរោគសញ្ញាជំងឺរបេងទេ ប៉ុន្តែគិតថាអ្នកមានការប៉ះពាល់នឹងជំងឺរបេង អ្នកគួរតែទទួលបានការព្យាបាលបង្ការ។

ប្រភេទម៉ាសខុសគ្នាមួយចំនួន អាចជួយទប់ស្កាត់ការរីករាលដាលនៃជំងឺរបេង។ អ្នកជំងឺរបេងអាចពាក់ម៉ាស់វះកាត់ឬរបាំងក្រណាត់  ពីព្រោះវាអាចបញ្ឈប់មេរោគរបេងនៅពេលដែលពួកគេក្អក ដោយមិនឱ្យរាលដាលទៅខ្យល់។ ប្រសិនបើអ្នកថែទាំមនុស្សដែលមានជំងឺរបេង  ប៉ុន្តែអ្នកមិនឈឺទេ  ប្រភេទពិសេសនៃរបាំងម៉ាស់ចាំបាច់ត្រូវពាក់ដើម្បីការពារការដកដង្ហើមស្រូបយកមេរោគរបេង។ វត្ថុនេះត្រូវបានគេហៅថាឧបករណ៍ដកដង្ហើម N-95 ហើយវា ទប់ស្កាត់បាននូវការហូរចូល និងស្រូបចូលនៃមេរោគ។  ប្រសិនបើអ្នកមិនមានជំងឺរបេង  និងកំពុងព្យាយាមការពារខ្លួនអ្នក  សូមកុំពាក់ម៉ាសវះកាត់ធម្មតាព្រោះវាពិតជាអាក្រក់ជាងការមិនពាក់ម៉ាស់ទៅទៀត។



*Photo Credit: Delek Hospital*

# ដឹងអំពីសិទ្ធិរបស់អ្នក

## ការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺរបេង

## សិទ្ធិ និងការធ្វើរោគវិនិច្ឆ័យ

ដោយ GISA DANG

កែសំរួលដោយ Tsira Chakhaia, Brian Citro, Vivian Cox, Mike Frick, Jennifer Furin, Erica Lessem, Alexander William Mbuya, Lindsay McKenna, John Mdluli, Jane Rahedi Ong’ang’o, Hadija H. Semvua, and Zani de Wit



### តើខ្ញុំដឹងដោយរបៀបណា ថាខ្ញុំត្រូវការធ្វើតេស្តរកជំងឺរបេង ?

ប្រសិនបើអ្នកក្អកលើសពី ពីរសប្តាហ៍ ស្រកទម្ងន់ ក្អកចេញឈាម ឬចេញញើសពេលយប់ អ្នកគួរតែធ្វើតេស្តរកជំងឺរបេង។ប្រសិនបើអ្នកមានផ្ទុកមេរោគអេដស៍ អ្នកគួរតែត្រូវបានធ្វើតេស្តជាទៀងទាត់រកជំងឺរបេង។ ដំបូងអ្នកអាចត្រូវបានគេសួរអំពីរោគសញ្ញាទាំងនេះ ឬតម្រូវអោយថតដោយកាំរស្មី X-ray ។ ការធ្វើបែបនេះ អាចផ្តល់ព័ត៌មានអំពីថាតើអ្នកត្រូវការធ្វើតេស្តរកជំងឺរបេងដែរឬទេ។ កាំរស្មី X-ray មិនមែនជាការធ្វើតេស្តជំងឺរបេងដោយខ្លួនឯងទេ ព្រោះមានអ្វីៗជាច្រើនដែលមិនមែនជាជំងឺរបេង អាចមើលទៅដូចជំងឺរបេងនៅលើកាំរស្មី X-ray ដូចនេះតម្រូវឱ្យមានការធ្វើតេស្តជំងឺរបេងជាក់លាក់បន្ថែមទៀត ប្រសិនបើសង្ស័យថាអ្នកមានជំងឺរបេង ដែលថតចេញពីកាំរស្មី X-ray ។

### តើជំងឺរបេងគួរតែត្រូវបានគេធ្វើរោគវិនិច្ឆ័យដូចម្តេច ?

អ្នកដែលកំពុងធ្វើតេស្តរកជំងឺរបេងគួរតែមានសិទ្ធិចូលទៅ GeneXpert MTB / RIF ឬ GeneXpert MTB /RIF Ultra ជាការធ្វើតេស្តដំបូង (ជួនកាលគេហៅថាតេស្ត CBNAAT) ។ GeneXpert អាចផ្តល់លទ្ធផលបានលឿន និងមានភាពត្រឹមត្រូវជាងការធ្វើតេស្តកំហាកតាមមីក្រូស្កុបធម្មតា។ នេះគឺជាការពិតសម្រាប់មនុស្សពេញវ័យ និងកុមារនិងសម្រាប់មនុស្សរស់នៅជាមួយមេរោគអេដស៍។ ប្រសិនបើ GeneXpert មិនរកឃើញជំងឺរបេងទេ ប៉ុន្តែអ្នក ឬអ្នកថែទាំសុខភាពរបស់អ្នកកំពុងតែព្រួយបារម្ភថាអ្នកមានជំងឺរបេង អ្នកមានសិទ្ធិធ្វើតេស្តរោគវិនិច្ឆ័យបន្ថែមទៀតបាន។ GeneXpert គួរតែ មិនមែនជាការធ្វើតេស្តដំបូងបំផុតនៃជំងឺរបេងទេ នៅពេលនរណាម្នាក់ក្លាយជាអ្នកមានជំងឺធ្ងន់ធ្ងរ និងមានមេរោគអេដស៍។ ដូច្នេះទាំងការធ្វើតេស្តទៅលើទឹកនោមដោយ LAM និង GeneXpert នឹងត្រូវយកមកប្រើ សូមមើលរូបខាងក្រោម

DR-TB STAT
TAG Treatment Action Group
www.treatmentactiongroup.org

កុម្ភៈ 2018

# សិទ្ធិ និងការធ្វើរោគវិនិច្ឆ័យ



ទោះបីជា GeneXpert ជាឧបករណ៍ធ្វើតេស្តដំបូងគេ តែនៅកន្លែងជាច្រើននៅតែប្រើប្រាស់មីក្រូស្កុបជាការធ្វើតេស្តដំបូង។ ប្រសិនបើនេះជាករណីនៅក្នុងកន្លែងដែលអ្នករស់នៅអ្នកប្រហែលជាចង់លើកទឹកចិត្តរដ្ឋាភិបាលរបស់អ្នកឱ្យធ្វើការអភិវឌ្ឍន៍គោលនយោបាយ សំរាប់ការធ្វើរោគវិនិច្ឆ័យរោគរបេងដោយយោងទៅតាមសិទ្ធិទទួលបានវិទ្យាសាស្រ្ត និងសិទ្ធិសុខភាព។

## តើកុមារគួរធ្វើតេស្តរកជំងឺរបេងយ៉ាងដូចម្តេច?

ការធ្វើរោគវិនិច្ឆ័យអាចជាបញ្ហាប្រឈមច្រើនចំពោះកុមារ ពីព្រោះពួកគេមានបាក់តេរីតិចជាងមនុស្សពេញវ័យនិងអាចមានបញ្ហាក្នុងការក្អកយកកំហាក។ កុមារគួរតែត្រូវបានផ្តល់ឱ្យជាប្រចាំនូវកាំរស្មីX-ray និងអាចត្រូវការវិធីសាស្រ្តបន្ថែមទៀតសម្រាប់ការទទួលបានគំរូមួយដែលអាចត្រូវបានធ្វើតេស្តនៅលើ GeneXpert (ហៅថាថ្នាំ gastric aspirate) ។

## ចុះចំពោះការធ្វើរោគវិនិច្ឆ័យជំងឺរបេងស៊ាំនឹងថ្នាំ?

ដើម្បីធ្វើឱ្យការព្យាបាលជំងឺរបេងមានប្រសិទ្ធិភាព គឺជំងឺរបេងរបស់អ្នកគួរតែឆាប់ទទួលបានថ្នាំដែលអ្នកកំពុងព្យាបាល។ វាគឺជាការចាំបាច់ដើម្បីរកឱ្យឃើញឆាប់ ថាតើជំងឺរបេងរបស់អ្នកមានភាពស៊ាំនឹងថ្នាំ(មិនងាយទទួលយក) ចំពោះថ្នាំណាមួយក្នុងការព្យាបាលរបស់អ្នក។ ការធ្វើរោគវិនិច្ឆ័យជំងឺរបេងដែលស៊ាំនឹងថ្នាំ ក៏ត្រូវបានគេហៅថាការធ្វើតេស្តងាយនឹងទទួលថ្នាំ ឬ DST ។ GeneXpert អាចរកឃើញភាពប្រឆាំងទៅនឹងឱសថ rifampicin ។ ការធ្វើតេស្តមួយផ្សេងទៀតដែលហៅថា ការធ្វើការស៊ើបអង្កេត (line probe assay) អាចប្រាប់បានក្នុងរយៈពេល ពីរ បីថ្ងៃ ប្រសិនបើអ្នកជំងឺរបេងមានភាពស៊ាំទៅនឹងថ្នាំដ៏សំខាន់ផ្សេងទៀតរួមទាំង isoniazid, ថ្នាំចាក់ជួរជាទីពីរ (the second-line injectables) (amikacin, capreomycin, kanamycin), and fluoroquinolones (levofloxacin, moxifloxacin)។ ការធ្វើការស៊ើបអង្កេត (Line probe assays) គួរត្រូវមាន។ ប្រសិនបើមិនអាចធ្វើទៅបាន នោះការបណ្តុះវត្ថុរាវ (ដែលចំណាយពេលពីរបីសប្តាហ៍) ក៏គួរត្រូវបានយកមកប្រើបានផងដែរ។

# សិទ្ធិ និងការធ្វើរោគវិនិច្ឆ័យ




## ចុះបើខ្ញុំរស់នៅជាមួយមេរោគអេដស៍?

ការធ្វើរោគវិនិច្ឆ័យជំងឺរបេងចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍អាចមានការពិបាកជាងនេះ ពីព្រោះអ្នកផ្ទុកមេរោគអេដស៍អាចមានកម្រិតខុសៗគ្នានៃជំងឺរបេងនៅក្នុងសួតរបស់ពួកគេ ហើយជារឿយៗមានជំងឺរបេងនៅក្រៅសួត (ជំងឺរបេងក្រៅសួត)។ ម៉ាស៊ីន GeneXpert ជាពិសេស MTB / RIF ឬទឹកថ្នាំពិសេស (Ultra cartridge) មានលក្ខណៈល្អប្រសើរក្នុងការរុករកជំងឺរបេង - រួមទាំងជំងឺរបេងក្រៅសួត - នៅក្នុងខ្លួនអ្នកមានផ្ទុកមេរោគអេដស៍ បានប្រសើរជាងការរុករកជំងឺរបេង ដោយការដាក់កំហាកក្នុងមីក្រូទស្សន៍។

ឧបករណ៍រកជំងឺរបេងបែបថ្មី ដែលគេហៅថា TBLAM គឺជាឧបករណ៍ធ្វើតេស្តបែបថ្មីមួយដែលអាចរកឃើញរោគ របេងនៅក្នុងទឹកនោម។ អង្គការសុខភាពពិភពលោកណែនាំឱ្យធ្វើតេស្ត ដោយប្រើឧបករណ៍ TBLAM គឺអាចប្រើបានតែសំរាប់អ្នកដែលរស់នៅជាមួយមេរោគអេដស៍មានកោសិកា CD4 ≤100 កោសិកា / មីល្លីម៉ែត្រគីប ឬសម្រាប់អ្នកជំងឺដែលមានជំងឺអេដស៍ធ្ងន់ធ្ងរ។ ប្រសិនបើការធ្វើតេស្តដោយប្រើឧបករណ៍ TBLAM មានលទ្ធផលវិជ្ជមាន អ្នកគួរតែចាប់ផ្តើមព្យាបាលភ្លាម ដោយមិនចាំបាច់រង់ចាំការធ្វើតេស្តផ្សេងទៀតនោះឡើយ។ ការធ្វើតេស្តដោយប្រើឧបករណ៍ TBLAM អាចនឹងរកមិនឃើញនូវជំងឺរបេងខ្លះ ដូច្នេះប្រសិនបើការធ្វើតេស្ត ដោយប្រើឧបករណ៍ TBLAM មានលទ្ធផលអវិជ្ជមាន អ្នកប្រហែលជានៅតែមានជំងឺរបេង ហើយជាការចាំបាច់ដែលអ្នកត្រូវធ្វើតាមដានបន្តដោយប្រើម៉ាស៊ីន GeneXpert ។

# សិទ្ធិ និងការធ្វើរោគវិនិច្ឆ័យ



## ចុះបើខ្ញុំមានផ្ទៃពោះ ?

ការមានផ្ទៃពោះគឺជាឱកាសមួយដើម្បីទទួលការថែទាំសុខភាព។ក្នុងករណីខ្លះ ការមានផ្ទៃពោះអាចបង្កើនហានិភ័យនៃការវិវត្តទៅជាជំងឺរបេង។ប្រសិនបើអ្នករស់នៅក្នុងស្ថានភាពដែលមានអត្រាខ្ពស់នៃជំងឺរបេង អ្នកគួរតែសួរគ្រូពេទ្យរបស់អ្នកអំពីការធ្វើតេស្តរកមេរោគរបេង។ដោយសារតែរោគសញ្ញាមិនដំណើរការល្អ ចំពោះស្ត្រីមានផ្ទៃពោះ អ្នកគួរតែស្នើសុំការធ្វើតេស្តជាមួយម៉ាស៊ីន GeneXpert ឬការធ្វើតេស្តសារធាតុរាវយ៉ាងរហ័សជាពិសេស ប្រសិនបើអ្នករស់នៅជាមួយមេរោគអេដស៍។ យោងតាមអង្គការសុខភាពពិភពលោក កាំរស្មី X-ray មិនបង្កឱ្យមានគ្រោះថ្នាក់ខ្លាំងក្លាណាមួយសម្រាប់ទារកដែលកំពុងលូតលាស់របស់អ្នកនោះទេ ដរាបណាគ្រូពេទ្យរបស់អ្នកអនុវត្តន៍ល្អ ដូចជាផ្តល់ឱ្យអ្នកនូវអាវអៀមដែលមានសារជាតិសំណដើម្បីពាក់លើពោះរបស់អ្នក។

## តើខ្ញុំអាចត្រូវបង្ខំឲ្យធ្វើតេស្តដែរឬទេ ?

ការធ្វើតេស្តរកមេរោគរបេងគួរតែត្រូវបានធ្វើឡើងតែជាមួយនឹងការព្រមព្រៀងរបស់អ្នកប៉ុណ្ណោះ។អ្នកផ្តល់សេវាមួយចំនួនឬនិតិវិធីសម្រាប់អន្តោប្រវេសន៍ តម្រូវឱ្យធ្វើតេស្តរកមេរោគឬជំងឺរបេង។ ទោះជាយ៉ាងណាក៏ដោយការធ្វើតេស្តវិជ្ជមានមិនគួររារាំងអ្នកមិនឱ្យធ្វើការ ឬរស់នៅក្នុងប្រទេសមួយផ្សេងទៀតទេ។ ប្រសិនបើការធ្វើតេស្តរបស់អ្នកបង្ហាញ ថាអ្នកមានមេរោគរបេង ឬជំងឺរបេង អ្នកគួរតែទទួលបានការព្យាបាល។



# ដឹងអំពីសិទ្ធិរបស់អ្នក

## ការបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺរបេង

## សិទ្ធិ និងការព្យាបាលជំងឺរបេង

**ដោយ GISA DANG**

កែសំរួលដោយ Tsira Chakhaia, Brian Citro, Vivian Cox, Mike Frick, Jennifer Furin, Erica Lessem, Alexander William Mbuya, Lindsay McKenna, John Mdluli, Jane Rahedi Ong’ang’o, Hadija H. Semvua, and Zani de Wit



### តើខ្ញុំគួរតែទទួលការព្យាបាលរបេងនៅកន្លែងណា?

ការព្យាបាលជំងឺរបេងគួរតែត្រូវបានកំណត់ថា ជាន្លែងមានភាពងាយស្រួលសម្រាប់អ្នក។ ឧទាហរណ៍ នៅឯគ្រូពេទ្យថែទាំសុខភាពបឋម ឬមណ្ឌលសុខភាពសហគមន៍ដែលនៅជិតកន្លែងដែលអ្នករស់នៅ ឬធ្វើការឬដោយមានបុគ្គលិកថែទាំសុខភាពមកផ្ទះរបស់អ្នកប្រសិនបើអ្នកមានអារម្មណ៍ថា មានភាពងាយស្រួលនោះ ឬដោយទទួលយកវានៅផ្ទះដោយអ្នកផ្តល់សេវាមកត្រួតពិនិត្យសុខភាពជាប្រចាំ។ ប្រសិនបើការព្យាបាលជំងឺរបេងមិនមានភាពងាយស្រួលនៅកន្លែងដែលអ្នករស់នៅទេ អ្នកប្រហែលជាចង់លើកទឹកចិត្តរដ្ឋាភិបាលរបស់អ្នកឱ្យអភិវឌ្ឍគោលនយោបាយរបស់ខ្លួនសម្រាប់ការថែទាំព្យាបាលជំងឺរបេង តាមសហគមន៍ស្របតាមសិទ្ធិទទួលបានពីវិទ្យាសាស្ត្រ និងសិទ្ធិទទួលបានសុខភាព។

### ហេតុអ្វីជាទូទៅ ការស្នាក់នៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺរបេងគឺមិនចាំបាច់?

អ្នកមិនគួរស្នាក់នៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺរបេង ឬក៏ព្យាបាលជំងឺរបេងស៊ាំថ្នាំនោះទេលុះត្រាតែវាចាំបាច់ណាស់។ ការស្នាក់នៅមន្ទីរពេទ្យមិនត្រូវបានទាមទារ ឬត្រូវបានគេពេញចិត្តទេចំពោះករណីភាគច្រើន។ មន្ទីរពេទ្យដែលមានខ្យល់អាកាសមិនល្អអាចចម្លងមេរោគរបេងបាន។ ការស្នាក់នៅមន្ទីរពេទ្យមានតម្លៃថ្លៃជាង។ ជួនកាលមន្ទីរពេទ្យមិនមានកន្លែងគ្រប់គ្រាន់ទេ មានន័យថាអ្នកជំងឺត្រូវតែរង់ចាំ ដើម្បីចាប់ផ្តើមព្យាបាល។

DR-TB STAT
TAG Treatment Action Group
www.treatmentactiongroup.org
មករា 2018

## តើខ្ញុំត្រូវស្នាក់នៅមន្ទីរពេទ្យនៅពេលណា ?

អ្នកមិនចាំបាច់ត្រូវស្នាក់នៅមន្ទីរពេទ្យដោយស្វ័យប្រវត្តិទេក្នុងរយៈពេលនៃការព្យាបាល។ តែប្រសិនបើអ្នកឈឺខ្លាំង ឬប្រសិនបើអ្នកមានផលប៉ះពាល់ដែលត្រូវពិនិត្យយ៉ាងដិតដល់ គ្រូពេទ្យរបស់អ្នកអាចណែនាំឲ្យអ្នកស្នាក់ នៅមន្ទីរពេទ្យ។ មន្ទីរពេទ្យខ្លះមានសេវាល្អក្នុងការថែទាំមនុស្សដែលមានជំងឺរបេង និងការពារការរីករាលដាលនៃជំងឺរបេងនិងអាចផ្តល់នូវបរិយាកាសគាំទ្រសម្រាប់ព្យាបាល ជាពិសេសចំពោះអ្នកដែលមានជំងឺរបេងស្មុគស្មាញ ដូច្នេះមានពេលខ្លះការចូលមន្ទីរពេទ្យនឹងក្លាយជាជំរើសល្អបំផុត។ អ្នកមិនគួរស្នាក់នៅក្នុងមន្ទីរពេទ្យជាលក្ខខណ្ឌដើម្បីទទួលបានការព្យាបាល នូវឱសថប្រភេទថ្មីនោះទេ។

## តើខ្ញុំគួរប្រើប្រាស់ការព្យាបាល/ថ្នាំអ្វីខ្លះ ?

អ្នកគួរតែប្រើឱសថដែលមានប្រសិទ្ធភាពសម្រាប់ព្យាបាលជំងឺរបេងដែលត្រូវនឹងអ្នក។អ្នកជំងឺរបេងដែលបានទទួលការព្យាបាលធម្មតាត្រូវចំណាយពេល 6 ខែនៃការព្យាបាលប្រចាំថ្ងៃ។ អង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍ការរួមបញ្ចូលគ្នានូវថ្នាំប្រចាំថ្ងៃដែលរួមបញ្ចូលថ្នាំខុសៗគ្នាទៅក្នុងគ្រាប់មួយ និងធ្វើឱ្យអ្នកងាយ ស្រួលក្នុងការព្យាបាល។សម្រាប់អ្នកជំងឺរលាកខ្នែងពោះវៀន (ជម្ងឺរបេងនៃប្រព័ន្ធសរសៃប្រសាទ ដូចជាខួរក្បាល) និងជម្ងឺរបេងឆ្អឹង និងសន្លាក់ត្រូវការការព្យាបាលរយៈពេល 12 ខែ។

សម្រាប់ជំងឺរបេងស៊ាំថ្នាំច្រើនមុខ ឥឡូវនេះមានការព្យាបាលខ្លីជាង 9 ទៅ 12 ខែ( ទោះបីជាភ័ស្តុតាងបង្ហាញពីប្រសិទ្ធភាពថ្នាំនៅមិនទាន់ច្បាស់លាស់នៅឡើយទេ )។ មិនមែនគ្រប់គ្នាសុទ្ធតែមានសិទ្ធិទទួលការព្យាបាលរយៈពេលខ្លីនេះទេ។ ប្រសិនបើអ្នកមិនអាចប្រើការព្យាបាលខ្លីជាងនេះទេព្រោះអ្នកបានប្រើឱសថមួយចំនួនរួចមកហើយ ឬដោយសារការធ្វើតេស្តរបស់អ្នកបង្ហាញពីភាពស៊ាំចំពោះឱសថមួយចំនួនក្នុងនោះ អ្នកគួរតែមានវិធីព្យាបាលយូរជាងនេះ ( 18-24 ខែ ) ដែលរួមបញ្ចូលទាំងថ្នាំថ្មី Bedaquiline ឬ Delamanid។ មានការសិក្សាមួយចំនួនកំពុងបន្ត( ការសាកល្បងខាងវេជ្ជសាស្ត្រ ) ដើម្បីព្យាយាមស្វែងរកការព្យាបាលឱ្យបានប្រសើរជាងមុន។ អ្នកគួរសួរថាតើចំណុចណាមួយទាំងនេះកំពុងត្រូវបានធ្វើនៅក្នុងតំបន់របស់អ្នក។អ្នកគួរតែស្គាល់ឈ្មោះឱសថជាក់លាក់របស់អ្នក របៀបប្រើវាជាញឹកញាប់ ត្រូវលេបប៉ុន្មានគ្រាប់ និងផលរំខានទូទៅបំផុតដែលអ្នកត្រូវប្រយ័ត្ន។

## តើការព្យាបាលបែបណា ដែលត្រូវបានណែនាំសម្រាប់កុមារ ?

ការព្យាបាលបែបពិសេសបានធ្វើឡើងសម្រាប់កុមារដែលព្យាបាលរបេងស៊ាំថ្នាំ ឥលូវនេះត្រូវបានអនុវត្តន៍ហើយ។ ថ្នាំថ្មីៗ ដែលត្រូវបានគេហៅថាថ្នាំផ្សំឬបញ្ចូលគ្នាគឺមានកម្រិតត្រឹមត្រូវសម្រាប់កុមារ ដូច្នេះពួកគេមិនត្រូវការការកំទេច ឬបំបែកអ្វីទេ។ ថ្នាំទាំងនោះរំលាយទាំងស្រុងនៅក្នុងទឹកហើយរសជាតិថ្នាំក៏ល្អប្រសើរជាងថ្នាំគ្រាប់របស់មនុស្សពេញវ័យ។

កុមារដែលមានជំងឺរបេងស៊ាំថ្នាំច្រើនមុខអាចទទួលបានការព្យាបាលរយៈពេលខ្លី។ ប្រសិនបើមានហេតុផលមួយដែលកុមារ មិនអាចទទួលយកថ្នាំរយៈពេលខ្លី នោះពួកគេគួរតែមានវិធីព្យាបាលយូរជាងនេះដែលត្រូវបានបង្កើតឡើងសម្រាប់ជំងឺរបេងរបស់ពួកគេ។ ប្រសិនបើជំងឺរបេងមិនមានលក្ខណៈទូលំទូលាយទេនោះ ថ្នាំដែលអាចចាក់បាន(ដែលបណ្តាលអោយមានផលប៉ះពាល់ជាច្រើនដែលអាចមើលឃើញនៅខាងក្រោម) អាចត្រូវបានដកចេញ។ ថ្នាំ Delamanid ត្រូវបានណែនាំអោយប្រើចំពោះកុមារដែលមានអាយុ ៦ ឆ្នាំ និងចាស់ជាងនេះ។ គ្រូពេទ្យរបស់អ្នកអាចស្នើសុំ Bedaquiline សម្រាប់មនុស្សវ័យជំទង់ដែលស្ថិតក្រោមការប្រើប្រាស់ដោយ សមហេតុផល(មានន័យថាការចូលប្រើការព្យាបាលមិនទាន់ត្រូវបានអនុម័តនៅក្នុងប្រទេសមួយឬសម្រាប់ប្រជាជនជាក់លាក់មួយ) ដោយសរសេរទៅ JanssenMAc@its.jnj.com ។

## ចុះបើខ្ញុំមានផ្ទៃពោះ ឬបំបៅ ឬប្រហែលជាមានផ្ទៃពោះ ?

ប្រសិនបើអ្នកមានជំងឺរបេង និងមានផ្ទៃពោះ ឬអាចមានផ្ទៃពោះអ្នកប្រហែលជាត្រូវធ្វើការសម្រេចចិត្តដ៏ពិបាកទាក់ទងនឹងវិធីល្អបំផុតដើម្បីថែរក្សាខ្លួនឯង និងកូនៗរបស់អ្នក។ មិនមានព័ត៌មានច្រើនទេស្តីពីសុវត្ថិភាពនៃថ្នាំរបេងចំពោះអ្នកមានផ្ទៃពោះឬអ្នកដែលស្ថិតក្នុងការបំបៅដោះកូន។សុខភាពរបស់អ្នកពិតជាសំខាន់ណាស់សម្រាប់ផ្តល់សុខភាពល្អដល់កូនអ្នក បើអ្នកមានផ្ទៃពោះ ឬកំពុងបំបៅដោះកូនអ្នកគួរតែពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក អំពីការប្រឈមនឹងហានិភ័យនិងអត្ថប្រយោជន៍នៃជម្រើសផ្សេងគ្នា និងធ្វើការសម្រេចចិត្តនូវអ្វីដែលល្អបំផុតសម្រាប់អ្នក។ អ្នកអាចមិនចង់ប្រើថ្នាំមួយចំនួន ឬអ្នកប្រហែលជាចង់បញ្ឈប់ការបំបៅ ឬការមានគភ៌របស់អ្នក(ការរំលូតកូន)។ ប្រសិនបើអ្នកមិនមានផ្ទៃពោះទេ ប៉ុន្តែកំពុងព្យាបាលជំងឺរបេងនិងអាចមានផ្ទៃពោះអ្នកគួរតែសួរអ្នកផ្តល់សេវាអំពីជម្រើសគ្រប់គ្រងកំណើត។ថ្នាំពីរប្រភេទដែលត្រូវបានប្រើដើម្បីព្យាបាលជំងឺរបេងស៊ាំថ្នាំច្រើនមុខ Ethionamide (ឬថ្នាំស្រដៀងគ្នា Prothionamide) និងថ្នាំដែលអាចចាក់បាន (amikacin, capreomycin, kanamycin, streptomycin) ត្រូវបានគេគិតថាមានគ្រោះថ្នាក់ខ្លាំងចំពោះទារកដែលកំពុងលូតលាស់។ ថ្នាំទាំងនេះ គឺជាផ្នែកមួយនៃការព្យាបាលរយៈពេលខ្លី ដូច្នេះស្ត្រីមានផ្ទៃពោះដែល

មានជម្ងឺរបេងស៊ាំថ្នាំច្រើនមុខ មិនមានសិទ្ធិទទួលការព្យាបាលរយៈពេលខ្លីនោះទេ។ ផ្ទុយទៅវិញស្តង់ដារពិភពលោកណែនាំថា ស្ត្រីមានផ្ទៃពោះដែលមានជំងឺរបេងស៊ាំថ្នាំច្រើនមុខ ត្រូវទទួលបានការព្យាបាលដោយប្រើថ្នាំយូរជាងមុន (ដែលត្រូវបានបង្កើតឡើងសម្រាប់ជំងឺរបេងពិសេស ជាមួយនឹងថ្នាំជួរទីពីរ ពីបួនទៅច្រើន ដែលមានប្រសិទ្ធភាព) ។ កម្មវិធីថ្នាក់ជាតិមួយចំនួន ដែលរីកចម្រើនរួមទាំងនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងកំពុងប្រើថ្នាំថ្មី Bedaquiline ឬ Delamanid នៅក្នុងរបបអាហារដែលមានរយៈពេលយូរជាងនេះសម្រាប់ស្ត្រីមានផ្ទៃពោះ។ ដោយផ្អែកលើព័ត៌មាន ដែលមានរហូតមកដល់ពេលនេះ ថ្នាំទាំងពីរប្រភេទនេះត្រូវបានគេគិតថាមានសុវត្ថិភាព សម្រាប់ស្ត្រីមានផ្ទៃពោះ។ វេជ្ជបណ្ឌិតរបស់អ្នកអាចស្នើសុំឱសថទាំងនេះសម្រាប់ស្ត្រីមានផ្ទៃពោះ ដែលស្ថិតក្រោមការផ្តល់ដោយក្តីសប្បុរស ដោយការសរសេរស្នើសុំទៅ JanssenMAc@its.jnj.com សម្រាប់ bedaquiline និង medical@otsuka.de សម្រាប់ delamanid ។

## ចុះចំពោះផលរំខាន?

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកត្រូវតែប្រាប់អ្នកអំពីថ្នាំដែលអ្នកលេប ផលប៉ះពាល់ដែលមានសក្តានុពល និងរបៀបដែលពួកគេនឹងត្រូវបានត្រួតពិនិត្យ (ពិនិត្យឬសាកល្បង) ។ ប្រសិនបើអ្នកផ្តល់សេវាមិនបានផ្តល់ព័ត៌មានទាំងនោះអ្នកគួរតែសួរ។ ផលប៉ះពាល់ត្រូវបានគេរំពឹងទុកដូចជាទឹកនោមក្រហម ឬចង្អោរកម្រិតស្រាល ប៉ុន្តែមួយចំនួនទៀតធ្ងន់ធ្ងរដូចជាការខូចថ្លើម ការបាក់ទឹកចិត្ត ឬវិកលចរិត ឬការបាត់បង់ការស្តាប់ ឬចក្ខុវិស័យ។ ផលវិបាកទាំងនេះ គឺគេអាចបញ្ឈប់បានប្រសិនបើមានការដឹងជាមុន។ គ្រូពេទ្យរបស់អ្នក គួរតែពិនិត្យមើលថា អ្នកកំពុងមានស្ថានភាពល្អប្រសើរជាងមុនហើយឬនៅ ដោយរាប់ទាំងការពិនិត្យមើលនូវផលរំខានរបស់វា ៖

- ប្រភេទថ្នាំចាក់ (amikacin, capreomycin, kanamycin, streptomycin) អាចបណ្តាលអោយបាត់បង់ការស្តាប់។ អ្នកគួរតែតេស្តសាកល្បងការស្តាប់របស់អ្នក (ហៅថា audiometry) មុនពេលអ្នកចាប់ផ្តើមលេបថ្នាំ ហើយរៀងរាល់ខែនៅពេលបន្ទាប់ ដើម្បីឱ្យអ្នកដឹងពីផលប៉ះពាល់ បានលឿន។ ប្រសិនបើការធ្វើតេស្តរបស់អ្នក បង្ហាញពីការបាត់បង់សោតាវិញ្ញាណ ឬប្រសិនបើអ្នកកត់សម្គាល់នូវសញ្ញានៃការបាត់បង់សោតាវិញ្ញាណសូមបញ្ឈប់ភ្លាមៗនូវការចាក់ និងប្តូរទៅជាការប្រើប្រាស់ Delamanid ឬ Bedaquiline។ ប្រសិនបើការធ្វើតេស្តមិនមានទេអ្នកមានសិទ្ធិក្នុងការស្នើសុំឱសថផ្សេងទៀតដូចជា Bedaquiline ឬ delamanid ដើម្បីជំនួសការចាក់។

- ថ្នាំ Cycloserine និងផ្សេងទៀតអាចបណ្ដាលឱ្យមានការធ្លាក់ទឹកចិត្តនិងវិកលចរិត។ ប្រសិនបើអ្នកមានអារម្មណ៍ធ្លាក់ទឹកចិត្ត ឬអ្នកមិនចង់រស់ ចូរប្រាប់គ្រូពេទ្យអោយបានឆាប់ទើបអ្នកអាចប្តូរថ្នាំបានដោយសុវត្ថិភាព។

- ថ្នាំ Linezolid និងថ្នាំពេទ្យផ្សេងទៀតអាចបណ្ដាលឱ្យមានការឈឺចាប់ ស្ពឹក ការរលាក ឬការឈឺចាប់ដៃឬជើង។ ប្រសិនបើអ្នកមានអារម្មណ៍បែបនេះសូមប្រាប់គ្រូពេទ្យរបស់អ្នកភ្លាមៗ ដោយហេតុថា គេអាចបន្ថយកម្រិតថ្នាំ ឬបញ្ឈប់ការប្រើប្រាស់ថ្នាំមុនពេលមានការខូចខាតសរសៃប្រសាទជាអចិន្ត្រៃយ៍។ គ្រូពេទ្យរបស់អ្នកគួរតែពិនិត្យមើលរឿងនេះ នៅគ្រប់ពេលដែលគេមកពិនិត្យសុខភាពអ្នក។

- ថ្នាំរបេងជាច្រើនអាចធ្វើឱ្យខូចថ្លើមបាន។ អ្នកគួរតែមានការធ្វើតេស្តមុខងារថ្លើមជាទៀងទាត់ មុនពេលអ្នកចាប់ផ្តើមការព្យាបាល ហើយពិសេសប្រសិនបើអ្នកមានបញ្ហាថ្លើម ឬមានមេរោគអេដស៍។ ប្រសិនបើអ្នកធ្លាប់មានការចង្អោរក្អួតរមាស់ ឬការផ្លាស់ប្តូរពណ៌ស្បែក ឬភ្នែករបស់អ្នក អ្នកគួរតែស្នើសុំអ្នកផ្តល់សេវាសុខភាពរបស់អ្នកពិនិត្យមើលមុខងារថ្លើមរបស់អ្នក។ អ្នកគួរតែចៀសវាងការផឹកស្រានៅពេលដែលអ្នកប្រើថ្នាំរបេងប្រសិនបើអ្នកអាច។ ទោះជាយ៉ាងណាក៏ដោយ ការផឹកស្រាមិនគួរជាមូលហេតុនៃការមិនអោយអ្នកចាប់ផ្តើមការព្យាបាលនោះទេ (ដូចគ្នានឹងការប្រើថ្នាំញៀន ឬប្រើការព្យាបាលថ្នាំញៀនជំនួស opioid substitution therapy [OST])។

- Bedaquiline, Clofazimine, Delamanid និង Moxifloxacin (និងថ្នាំដទៃទៀត ដែលមិនមែនជាថ្នាំព្យាបាលជំងឺរបេង) អាចបណ្ដាលអោយមានការផ្លាស់ប្តូរនៅក្នុងសកម្មភាពចរន្តត់របស់បេះដូង (ដែលហៅថាកោសិកា QT)។ នេះអាចនាំឱ្យមានបញ្ហាធ្ងន់ធ្ងរជាមួយចង្វាក់បេះដូង។ ប្រសិនបើអ្នកប្រើថ្នាំមួយក្នុងចំណោមថ្នាំទាំងនេះ អ្នកគួរតែធ្វើតេស្តដែលហៅថា ECG (electrocardiogram) មុនពេលចាប់ផ្តើមការព្យាបាលហើយរយៈពេល ២សប្តាហ៍12 សប្តាហ៍ និង២៤សប្តាហ៍ បន្ទាប់ពីអ្នកចាប់ផ្តើម។ប្រសិនបើអ្នកប្រើថ្នាំច្រើនជាងមួយមុខ ក្នុងចំណោមថ្នាំទាំងនេះ អ្នកគួរតែទទួលបាន ECG ប្រចាំខែ។

- ប្រសិនបើអ្នកក្អួត ឬរាគ ឬប្រើថ្នាំដូចជា: amikacin, capreomycin, kanamycin, streptomycin, bedaquiline, clofazimine, delamanid, or moxifloxacin អ្នកគួរតែពិនិត្យមើលជាតិប៉ូតាស្យូម។ ប៉ូតាស្យូមគឺជាសារធាតុរ៉ែម្យ៉ាងនៅក្នុងខ្លួនរបស់មនុស្ស ដូចជាអំបិល។ ប្រសិនបើកម្រិតប៉ូតាស្យូមរបស់អ្នកទាបពេកឬខ្ពស់ពេក វាអាចបណ្តាលអោយមានបញ្ហាជាមួយនឹងសាច់ដុំ ជាមួយនឹងចង្វាក់បេះដូងរបស់អ្នក ឬជាមួយនឹងប្រព័ន្ធដទៃទៀតនៅក្នុងខ្លួនអ្នក។ អ្នកគួរសួរគ្រូពេទ្យរបស់អ្នក ដើម្បីពិនិត្យមើលកម្រិតប៉ូតាស្យូមអោយបានទៀងទាត់ ដោយយកឈាមរបស់អ្នកទៅពិនិត្យ។

- អ្នកគួរទទួលបានសារធាតុម៉ាញ៉េស្យូមបន្ថែម និងជាតិអំបិលផ្សេងទៀត ដើម្បីជួយឱ្យរាងកាយរបស់អ្នកមានដំណើរការល្អ។អ្នកមិនត្រូវការធ្វើតេស្តម៉ាញ៉េស្យូមទេ អ្នកគួរតែទទួលបានវាដោយស្វ័យប្រវត្តិ។ សួរគ្រូពេទ្យ ឬវេជ្ជបណ្ឌិតរបស់អ្នកប្រសិនបើអ្នកកំពុងទទួលម៉ាញ៉េស្យូមដែលអ្នកមិនប្រាកដ ហើយបើសិនអ្នកមិនទាន់មាន សូមស្នើសុំវាពីគ្រូពេទ្យរបស់អ្នក។



*Photo Credit: KUDUwave™ Portable Audiometers*

## តើខ្ញុំអាចធ្វើការ ឬចូលរៀននៅកំឡុងពេលព្យាបាលបានដែរឬទេ ?

មនុស្សគ្រប់រូបដែលមានជំងឺរបេងអវិជ្ជមាន (មិនឆ្លង) គួរតែត្រូវបានអនុញ្ញាតឱ្យធ្វើការ ឬទៅសាលារៀន។ អ្នកមិនគួរត្រូវរង់ចាំរហូតដល់អ្នកបានបញ្ចប់ការព្យាបាល ដើម្បីត្រឡប់ទៅធ្វើការឬទៅសាលារៀនទេ។ អ្នកមិនគួរបាត់បង់ការងារដោយសារតែអ្នកមានជំងឺរបេងទេ។ ជំងឺរបេងមិនឆ្លងទេ បន្ទាប់ពីការព្យាបាលល្អប៉ុន្មានសប្តាហ៍ (ទោះបីជាអ្នកត្រូវតែបញ្ចប់ការព្យាបាលឱ្យបានពេញលេញដើម្បីធានាថាវាមិនវិលត្រឡប់មកវិញ)។ អ្នកមិនចាំបាច់ប្រាប់មិត្តរួមការងារ ឬមិត្តរួមថ្នាក់របស់អ្នកថាអ្នកកំពុងប្រើថ្នាំរបេងទេ។ និយោជក ឬសាលារៀនរបស់អ្នកត្រូវរក្សាស្ថានភាពប្រើប្រាស់ថ្នាំរបស់អ្នកជាលក្ខណៈឯកជន។ ប្រសិនបើមិត្តរួមការងារ ឬមិត្តរួមថ្នាក់របស់អ្នកត្រូវការពិនិត្យរកជំងឺរបេងនេះ គេគួរតែត្រូវបានធ្វើក្នុងវិធីដែលការពារសិទ្ធិរបស់អ្នកក្នុងការរក្សាភាពឯកជន និងការរក្សាការសម្ងាត់។

## តើអ្វីទៅជាការប្រឹក្សាយោបល់ ហើយហេតុអ្វីខ្ញុំគួរស្នើរកវា ប្រសិនបើខ្ញុំមិនទទួលបាន ?

ការផ្ដល់ប្រឹក្សាមានន័យថាអ្នកទទួលបានការគាំទ្រ ព័ត៌មាន និងការពន្យល់ជាច្រើនជាមួយនឹងការព្យាបាល របស់អ្នកដើម្បីឆ្លើយសំណួរ ចម្ងល់ និងជួយអ្នកបញ្ចប់ការព្យាបាល។ ការព្យាបាលជំងឺរបេងអាចជាការពិបាក ដោយត្រូវលេបថ្នាំគ្រាប់ជាច្រើន និងមានផលប៉ះពាល់។ ការផ្ដល់ប្រឹក្សាល្អ នឹងជួយអ្នកឱ្យយល់អំពីរោគរបេងល្អប្រសើរជាងមុន ជួយគាំទ្រអ្នក និងជួយអ្នកក្នុងការព្យាបាល។

## ចុះបើខ្ញុំរស់នៅជាមួយមេរោគអេដស៍ ?

មនុស្សជាច្រើនមានទាំងមេរោគអេដស៍ និងជំងឺរបេង ហើយការទទួលបានការព្យាបាលទាំងពីរនេះគឺសំខាន់។ ប្រសិនបើអ្នកប្រើវិធីព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ចូរប្រាកដថាគ្រូពេទ្យដឹងថាតើថ្នាំអ្វីដែលអ្នក កំពុងប្រើ។ មួយចំនួនតូចនៃថ្នាំរបេង និងមេរោគអេដស៍មិនដំណើរការបានល្អទេ ប៉ុន្តែវាអាចត្រូវបានដោះស្រាយដោយការកែតម្រូវនូវកម្រិតថ្នាំ ឬការផ្លាស់ប្ដូរថ្នាំរបស់អ្នក។ ប្រសិនបើអ្នកត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានផ្ទុកមេរោគអេដស៍ និងមេរោគរបេងក្នុងពេលតែមួយ នោះគ្រូពេទ្យរបស់អ្នកគួរតែចាប់ផ្តើមព្យាបាលមេរោគរបេងរបស់អ្នក ហើយនឹងចាប់ផ្ដើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) របស់អ្នកវិញបន្ទាប់ពី ពីរ ទៅបី សប្ដាហ៍។ នេះជាការសំខាន់ណាស់ដើម្បីចៀសវាងនូវប្រតិកម្មដែលមានគ្រោះថ្នាក់ដែលហៅថារោគសញ្ញាប្រតិកម្មឡើងវិញ។ អ្នកដែលមានកោសិកា CD4 ចំនួន <50 កោសិកា / មម ម៉ែត្រគីប គួរចាប់ផ្តើម ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) នៅពេលពីរសប្ដាហ៍។ អ្នកដែលមានកោសិកា CD4 ≥ 50កោសិកា / មម ម៉ែត្រគីប ឬ អ្នកដែលមានជំងឺរលាកស្រោមខួរ គួរចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) បន្ទាប់ពី ៨-១២ សប្ដាហ៍។

## តើអ្វីទៅជាការព្យាបាលប្រភេទទី 2?

អ្នកមិនគួរស្ថិតនៅក្នុងការព្យាបាលប្រភេទទី 2 ទេ។ ប្រភេទទី 2 គឺការព្យាបាលជាទូទៅនៃការព្យាបាលជំងឺរបេង ដែលបូកបន្ថែមជាមួយថ្នាំដែលអាចចាក់បាន Streptomycin។ អនុសាសន៍ពីមុន សម្រាប់អ្នកដែលបានបញ្ចប់ការព្យាបាលរបេង ប៉ុន្តែនៅតែមានជំងឺរបេងគឺត្រូវប្រើការព្យាបាលប្រភេទទី2 ។ នៅឆ្នាំ 2015 អង្គការសុខភាពពិភពលោកបានចេញ" សេចក្តីថ្លែងការណ៍អំពីការអនុវត្តល្អ" មួយប្រឆាំងនឹងការប្រើប្រាស់ការព្យាបាលប្រភេទទី 2។ អនុសាសន៍ថ្មីនេះ គឺដើម្បីធ្វើតេស្តភាពស៊ាំថ្នាំ ដើម្បីសម្រេចថាតើថ្នាំណាដែលមានប្រសិទ្ធភាពបំផុតសម្រាប់ប្រភេទជំងឺរបេង របស់អ្នក។ ប្រសិនបើគ្រូពេទ្យព្យាយាមផ្តល់ឱ្យអ្នកនូវប្រភេទទី 2 អ្នកគួរតែសួររកការធ្វើតេស្តភាពស៊ាំថ្នាំ និងការព្យាបាលដោយផ្អែកលើលទ្ធផលរបស់អ្នក។

## ប្រសិនបើខ្ញុំមិនចង់ធ្វើតាមការព្យាបាលដែលវេជ្ជបណ្ឌិតប្រាប់ខ្ញុំ តើខ្ញុំអាចត្រូវបង្ខំឲ្យប្រើវាបានដែរឬទេ?

ទេ អ្នកមិនអាចត្រូវបានគេបង្ខំបានទេ។ ស្តង់ដារអន្តរជាតិបានចែងច្បាស់ណាស់ថា បង្ខំអ្នកណាម្នាក់អោយទទួលការព្យាបាលរបេងប្រឆាំងនឹងឆន្ទៈរបស់ពួកគេគឺខុសសីលធម៌។ អ្នកមានសិទ្ធិទទួលយក ឬបដិសេធការព្យាបាលទាំងអស់ ឬការព្យាបាលជាពិសេស។ ដោយសារជំងឺរបេងឆ្លង (អាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់) ប្រសិនបើអ្នកបដិសេធការព្យាបាល អ្នកត្រូវតែចាត់វិធានការដើម្បីការពារអ្នកដទៃ។ នេះអាចរួមបញ្ចូលទាំងការស្នាក់នៅឯកោ ដែលមានន័យថារក្សាដង្ហើមរបស់អ្នកមិនឱ្យទៅដល់មនុស្សផ្សេងទៀត។ អ្នកអាចធ្វើដូច្នេះដោយពាក់របាំងមុខ ឬតាមរយៈការនៅដាច់ពីគេនៅក្នុងបន្ទប់មន្ទីរពេទ្យដែលមានខ្យល់ចេញចូលបានត្រឹមត្រូវ ឬនៅផ្ទះ។ នៅក្នុងករណីកម្រ រដ្ឋាភិបាលរបស់អ្នកអាចធ្វើឱ្យអ្នកស្ថិតនៅឯកោក្នុងការដកដង្ហើម ដែលនេះគឺជាវិធីចុងក្រោយប៉ុណ្ណោះ។ ការធ្វើបែប នេះត្រូវបានគេហៅថា ការដាក់ឱ្យ នៅឯកោមិនស្ម័គ្រចិត្ត។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនគួរធ្វើដូច្នេះនៅក្នុងបន្ទប់ឃុំឃាំង ឬ កន្លែងស្រដៀងគ្នាទេ។

ដោយសារតែកុមារជាញឹកញាប់ ត្រូវការការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលដើម្បីយល់ព្រមការព្យាបាល វាគឺអាស្រ័យលើអាណាព្យាបាលឬអាណាព្យាបាលទទួល ឬបដិសេធការព្យាបាលជំនួសពួកគេ។ នៅពេលឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់បដិសេធមិនផ្តល់ការយល់ព្រម ប៉ុន្តែការព្យាបាលវេជ្ជសាស្ត្រត្រូវបានចាត់ទុកថាចាំបាច់ដើម្បីបង្ការការឈឺចាប់ ឬការស្លាប់រួមទាំងជំងឺរបេង នោះអាជ្ញាធររដ្ឋាភិបាលអាចចាត់វិធានការដើម្បីលុបចោលការសម្រេចចិត្តរបស់មាតាបិតា។ នេះអាចគ្រាន់តែកើតឡើងតាមរយៈយន្តការផ្អែកច្បាប់សមស្របទៅតាមច្បាប់នៃប្រទេសរបស់អ្នក។

## ខ្ញុំកំពុងថែរក្សាសមាជិកគ្រួសារដែលមានជំងឺរបេង។ តើខ្ញុំត្រូវដឹងអំពីអ្វីខ្លះ ?

អ្នកអាចថែរក្សាទាំងខ្លួនអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកដែលមានជំងឺរបេងក្នុងពេលតែមួយ។ ដើម្បីថែរក្សាខ្លួនអ្នក ចូរគិតអំពីសុខភាពរាងកាយ និងចិត្តរបស់អ្នក។ អ្នកគួរតែមានសិទ្ធិពិគ្រោះយោបល់ និងមានព័ត៌មានអំពីវិធីការពារខ្លួនអ្នកឱ្យល្អបំផុតពីជំងឺរបេង ( សូមមើលផ្នែកទី 2 ក្នុងវគ្គ "សិទ្ធិ និងការបង្ការជំងឺរបេង ") ។

ប្រសិនបើមនុស្សដែលអ្នកកំពុងថែទាំនៅតែក្អក ឬមិនឡើងទម្ងន់បន្ទាប់ពីប៉ុន្មានសប្តាហ៍នៃការព្យាបាលពួកគេគួរតែមានលទ្ធភាពទទួលបានការធ្វើតេស្តភាពស៊ាំថ្នាំដើម្បីធានាថាថ្នាំរបស់ពួកគេគឺត្រឹមត្រូវសម្រាប់ជំងឺរបេងរបស់ពួកគេ។ អ្នកអាចជួយរកមើលផលប៉ះពាល់ណាមួយហើយត្រូវប្រាកដថាពួកគេមាន សិទ្ធិក្នុងការធ្វើ តេស្តចំពោះផលរំខាននៅតាមពេលវេលា ត្រឹមត្រូវ ដូចដែលបានកត់សម្គាល់ខាងលើ។ អ្នកក៏អាចជួយពួកគេរក្សាការងាររបស់ពួកគេឬការស្នាក់នៅផងដែរប្រសិនបើពួកគេត្រូវបានរើសអើង។ការព្យាបាលជំងឺរបេងអាចជាការពិបាក ដូច្នេះប្រសិនបើអ្នកឬមនុស្សដែលអ្នកកំពុងយកចិត្តទុកដាក់ចង់ចាប់ផ្តើមឬចូលរួមក្នុងក្រុមគាំទ្រជំងឺរបេងអ្នកមានសិទ្ធិធ្វើដូច្នេះ។ ក្រុមគាំទ្រអាចជួយប្រយុទ្ធប្រឆាំងនឹងការមាក់ងាយដោយអប់រំអ្នកដទៃនៅក្នុងសហគមន៍របស់អ្នកអំពីជំងឺរបេង ជួយពួកគេឱ្យយល់ដឹងអំពីជំងឺរបេងគឺអាចការពារនិងព្យាបាលបាន។

សូមចងចាំថាបុគ្គលដែលអ្នកកំពុងថែរក្សាមានសិទ្ធឯកជនភាពហើយវាគួរតែជាការសម្រេចចិត្តរបស់ពួកគេថាតើពួកគេចង់ឱ្យមនុស្សដឹងថាពួកគេមានជំងឺរបេងដែរឬទេ។